**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការឃុំខ្លួនបណ្តោះអាសន្នក្នុងដំណាក់កាលចៅក្រមស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ លោក **ណុច មុនីសម្បត្តិ**

កញ្ញា **រ៉េត ច័ន្ទលក្ខិណា**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ណុប មុនីសម្បត្តិ** និងនាងខ្ញុំបាទឈ្មោះ **រ៉េត ច័ន្ទលក្ខិណា** ជានិស្សិតផ្នែកនីតិសាស្ត្រនៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា ២០២១-២០២២ ជំនាន់ទី ២២ ។ ជាដំបូងខ្ញុំបាទទាំងពីរនាក់ សូមថ្លែងអំណរគុណលំអោនកាយវាចាចិត្ត និងសម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ

| | | | |
|---|---|---|---|
| **លោកឪពុក** | **ណុប ច័ន្ទវន្នី** | **លោកឪពុក** | **ចាន់ ម៉ារិន** |
| **អ្នកម្តាយ** | **យិត សុយិម** | **អ្នកម្តាយ** | **អ៊ុន ស្រីមុំ** |

ដែលបានបង្កើតរូបកាយកូន និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ឧបត្ថម្ភរូបកូនគ្រប់បែបយ៉ាងតាំងពីតូចដល់ធំទាំងកម្លាំងកាយ ទាំងកម្លាំងចិត្តមិនគិតពីការនឿយហត់របស់លោកទាំងពីរនោះឡើយ និងបានឲ្យកូនរៀនសូត្រមានចំណេះដឹង រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ ។ គុណូបការៈយ៉ាងធំអនេក និងវិសេសវិសាលថ្លៃថ្លាបំផុតដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងពីរដែលជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំសម្រាប់កូនគ្រប់ៗរូបមានទំហំធំធេងរកអ្វីប្រៀបផ្ទឹមពុំបានឡើយ ។ ទង្វើរបស់លោកទាំងពីរធ្វើឲ្យកូនៗចងចាំជានិច្ចគ្មានថ្ងៃបំភ្លេចបាន ហើយនឹងស្ថិតក្នុងដួងព្រលឹងរបស់កូនៗជារៀងដរាបគ្មានថ្ងៃសូន្យនោះឡើយ ។

យើងទាំងពីរនាក់សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការផ្តល់នូវពុទ្ធិល្អៗយ៉ាងពិតប្រាកដសម្រាប់ជាយានបំភ្លឺជីវិតយើងខ្ញុំនៅក្នុងថ្នាក់បរិញ្ញាបត្រនេះ ។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **ជួន ម៉ិនធី** ដែលជា សាស្ត្រាចារ្យណែនាំ ដើម្បីធ្វើឲ្យមាននូវដំណើរការនៃការតាក់តែងសារណានេះឡើងប្រកបដោយភាពជោគជ័យ។ ជាពិសេសលោកបានចំណាយនូវកម្លាំងកាយកម្លាំងចិត្តនិងពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ប្រឹងប្រែងពន្យល់ណែនាំតម្រង់ទិសផ្តល់ឯកសារពាក់ព័ន្ធ និងអានុសាសន៍ល្អៗ និងជួយកែលម្អចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើយ៉ាងណាឲ្យសារណាយើងខ្ញុំបានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ ។ ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមប្រសិទ្ធិពរជ័យសិរីបវរជូនដល់ ***លោកអ្នកមានគុណ ទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តរួមថ្នាក់ និងរួមជំនាន់*** ទាំងអស់សូមប្រកបតែព្រះពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

# **អារម្ភកថា**

បន្ទាប់ពីបានឆ្លងកាត់ការសិក្សា និងក្រេបជញ្ជក់ចំណេះដឹងរយៈពេល ៤ ឆ្នាំនៅក្នុង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** យើងខ្ញុំក៏សម្រេចចិត្តជ្រើសរើសយក ប្រធានបទស្តីពី "**ការឃុំខ្លួនបណ្តោះអាសន្នក្នុងដំណាក់កាលចៅក្រមស៊ើបសួរ**" ដែលមានលោកសាស្ត្រាចារ្យដឹកនាំគឺ **លោក ជួន ម៉ុនធី** ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ។

ការសម្រេចជ្រើសរើសប្រធានបទខាងលើមកសិក្សាស្រាវជ្រាវ ជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះក៏ដោយសារតែយើងខ្ញុំយល់ឃើញថា វាមានសារៈសំខាន់ណាស់ដែលអ្នកអនុវត្តនីតិវិធីនៅតាមស្ថាប័នជម្រះក្តីទាំងអស់ត្រូវតែអនុវត្តឲ្យបានត្រឹមត្រូវ ។ ម៉្យាងវិញទៀត ការស្រាវជ្រាវនេះបានទទួលការយល់ព្រមការឯកភាព និងការលើកទឹកចិត្តពីលោកសាស្ត្រាចារ្យដឹកនាំសរសេរសារណាក្នុងការជំរុញឲ្យកិច្ចការនេះបានសម្រេចចេញជាលទ្ធផល។

ការស្រាវជ្រាវលើប្រធានបទនេះត្រូវបានចាប់ផ្តើម ដោយយកសារសិក្សាឯកសារច្បាប់ជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌ សៀវភៅណែនាំរបស់ក្រសួងយុត្តិធម៌ លិខិតណែនាំរបស់ក្រសួង យុត្តិធម៌ ព្រមទាំងឯកសារ និងលិខិតបទដ្ឋានគតិយុត្តនានាការសាកសួរយោបល់ផ្ទាល់ជាមួយចៅក្រម មេធាវី ក្រឡាបញ្ជី និងជំនួយការ មករួមបញ្ចូលគ្នា ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងពី ប្រសិទ្ធភាពនៃការអនុវត្តជាក់ស្តែងនូវខ្លឹមសារគតិយុត្តបញ្ហាប្រឈម ហេតុផល និងភាពខ្វះចន្លោះនៃការអនុវត្ត ។

ក្រោយពីស្រាវជ្រាវបានបញ្ចប់ ខ្ញុំបាទសង្ឃឹមថាសារណានេះនឹងក្លាយជាអត្ថបទដែលមាន សារៈប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវផ្នែកច្បាប់ទាំងអស់ ជាពិសេសអ្នកអនុវត្តនីតិវិធីនៅតាម ស្ថាប័នជម្រះក្តីនានា ។ ជាងនេះទៅទៀតវា នឹងក្លាយជាឯកសារមួយដែលបានចូលរួមចំណែក និងជំរុញដល់ការអនុវត្តច្បាប់ឲ្យកាន់តែមានប្រសិទ្ធភាព ហើយជាចំណែកនៃការផ្សព្វផ្សាយច្បាប់ និងការស្រាវជ្រាវផ្នែកនីតិវិធីព្រហ្មទណ្ឌឲ្យកាន់តែសម្បូរបែបផងដែរ ។

បើទោះបីជាមានការខិតខំស្រាវជ្រាវ និងការត្រួតពិនិត្យយ៉ាងហ្មត់ចត់យ៉ាងណាក៏ដោយ ក៏ការសរសេរសារណានេះពិតជាមានចំណុចមួយចំនួនដែលខ្វះខាត ដូចនេះយើងខ្ញុំទាំងពីរនាក់រង់ចាំទទួលការរិះគន់ពីសំណាក់សាស្ត្រាចារ្យ សិស្សនិស្សិតទាំងអស់ដើម្បីកែលម្អសារណានេះឲ្យកាន់តែមានលក្ខណៈល្អប្រសើរ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម ........................................................ ១**

## ជំពូកទី១

## គោលការណ៍ និងការឃុំខ្លួនបណ្តោះអាសន្ន

១.១ សញ្ញាណ និងគោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន ........................ ៤
១.១.១ សញ្ញាណទូទៅ........................................................ ៤
១.១.២ គោលការណ៍សេរីភាព ................................................ ៤
១.១.៣ គោលការណ៍សន្មតទុកជាមុនថាគ្មានទោស ................................ ៥
១.២ លក្ខខណ្ឌចាំបាច់ក្នុងការឃុំខ្លួនបណ្តោះអាសន្ន ................................ ៧
១.២.១ លក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទ........................................ ៧
១.២.២ លក្ខខណ្ឌនៃទោសដែលត្រូវដាក់ពន្ធនាគារ ................................ ៨
១.២.៣ លក្ខខណ្ឌនៃអាយុរបស់ជនត្រូវចោទ ........................................ ៩
១.៣. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ........................................ ៩
១.៣.១ ថិរវេលាឃុំខ្លួន នីតិជន ................................................ ១០
១.៣.១.១ ថិរវេលាឃុំខ្លួន នីតិជនក្នុងបទឧក្រិដ្ឋ ................................ ១០
១.៣.១.២ ថិរវេលាឃុំខ្លួន នីតិជនក្នុងបទមជ្ឈិម ................................ ១០
១.៣.២ ថិរវេលាឃុំខ្លួន អនីតិជន................................................ ១១
១.៣.២.១ ថិរវេលាឃុំខ្លួន អនីតិជនក្នុងបទឧក្រិដ្ឋ.................................. ១២
១.៣.២.២ ថិរវេលាឃុំខ្លួន អនីតិជនក្នុងបទមជ្ឈិម ................................ ១២
១.៤. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន........................................ ១៤

១. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី ........ ១៤
២. ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ........ ១៥
៣. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ........ ១៦
៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ........ ១៧
៥. ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ ........ ១៧
៦. ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស ........ ១៩
១.៤.២ មូលហេតុពិសេសផ្សេងទៀត ........ ១៩

## ជំពូកទី២

## នីតិវិធីស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន

២.១ ដំណើរការនីតិវិធីសម្រេចដាក់ឲឃុំខ្លួនបណ្តោះអាសន្ន ........ ២១
២.១.១ ការបង្ហាញខ្លួនលើកដំបូងនៃជនត្រូវចោទ ........ ២១
១.១.២ កិច្ចនៃការពិភាក្សាដេញដោលចំពោះមុខ ........ ២២
២.១.៣ នីតិវិធីចេញដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្ន ........ ២៣
២.១.៣.១ ដើមដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ........ ២៤
២.១.៣.២ ស្ថានភាពអង្គហេតុ និងអង្គច្បាប់ ........ ២៤
២.១.៣.៣ សំអាងហេតុនៃ និងសម្រេចបញ្ចប់ ........ ២៥
២.១.៤ ការសម្រេចទាក់ទង នឹងអនីតិជនអាយុក្រោម១៤ឆ្នាំ ........ ២៥
២.១.៥ អានុភាពនៃដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្ន ........ ២៥
២.២ ដីកាបង្គាប់ឲឃុំខ្លួនបណ្តោះអាសន្ន ........ ២៦
២.២.១ និយមន័យដីកាបង្គាប់ឲឃុំខ្លួន ........ ២៦

២.២.២ ការចុះនិទ្ទេសលើដីកាបង្គាប់ឲឃុំខ្លួន ........ ២៧

២.២.៣ ការអនុវត្តដីកាបង្គាប់ឲឃុំខ្លួន ........ ២៧

២.៣ សិទ្ធរបស់ជនត្រូវចោទក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ........ ២៨

២.៣.១ សិទ្ធក្នុងការស្នើសុំបំពេញកិច្ច ........ ២៨

២.៣.២ សិទ្ធស្នើសុំធ្វើកោសលវិច័យ ........ ២៩

២.៣.៣ សិទ្ធិស្នើសុំនៅក្រៅឃុំ ........ ៣០

២.៣.៤ សិទ្ធជ្រើសរើសជ្រើសរើស ឬស្នើសុំ ឬចាត់តាំង ឬផ្លាស់ប្ដូរមេធាវី ........ ៣១

២.៣.៥ សិទ្ធិប្ដឹងជិតចិត្ត ........ ៣២

២.៣.៦ សិទ្ធិទទួលបានដំណឹងពីការបិទបញ្ចប់សំណុំរឿង ........ ៣៣

២.៣.៧ . សិទ្ធិទទួលបានដំណឹងពីដីកាដំណោះស្រាយ ........ ៣៤

២.៣.៨ សិទ្ធិស្នើសុំឲ្យបិទសំណុំរឿង ........ ៣៥

២.៤ ការសម្រេចឲដោះលែងនៅក្រៅឃុំ ........ ៣៦

២.៤.១ ការដោះលែងជនត្រូវចោទនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ ........ ៣៦

២.៤.២ ការដោះលែងជនត្រូវចោទនៅក្រៅឃុំដោយបណ្ដឹងព្រះរាជអាជ្ញា ........ ៣៦

២.៤.៣ ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំដោយជនត្រូវចោទ ........ ៣៧

២.៤.៤ ការដោះលែងជនត្រូវចោទជាអនីតិជនឲនៅក្រៅឃុំ ........ ៣៨

២.៤.៥ ការជូនដំណឹងអំពីការដោះលែងឲនៅក្រៅឃុំ ........ ៣៩

២.៥ ការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៣៩

២.៥.១ ដីកាបង្គាប់ឲដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៤២

២.៥.២ កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៤២

២.៥.៣ ការដាក់ឱ្យអនីតិជនស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៤៣

២.៥.៤ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ........................................................................ ៤៤

២.៥.៤.១ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយឆន្ទានុសិទ្ធិ របស់ចៅក្រមស៊ើបសួរ.......... ៤៤

២.៥.៤.២ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា ..................................... ៤៤

២.៥.៤.៣ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ ..................................... ៤៥

២.៥.៥ ការគេចវេសពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ............................................... ៤៥

**សេចក្តីសន្និដ្ឋាន** ........................................................................................................ ៤៧

**អនុសាសន៍** .............................................................................................................. ៥០

**ឯកសារយោង**

**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជាជាប្រទេសនីតិរដ្ឋ ដោយយកច្បាប់ជាគោលក្នុងការដឹកនាំប្រទេសដែលបង្កើតឡើងដោយអង្គនីតិបញ្ញត្តិ ដើម្បីធ្វើការតាក់តែងទៅបទដ្ឋាននានាដែលជាតម្រូវការជាចាំបាច់សម្រាប់ដាក់ជូនប្រជាពលរដ្ឋគ្រប់រូបគោរពអនុវត្តតាមបញ្ញត្តិច្បាប់ទាំងនោះ។

ក្នុងនោះសង្កេតឃើញមានច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ០៨-០៣-១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មច្បាប់នីតិវិធីឆ្នាំ២០០១ និងត្រូវបាននិរាករណ៍ដោយក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើនៅថ្ងៃ ទី១០ ខែសីហា ឆ្នាំ២០០៧ ។

នីតិវិធិព្រហ្មទណ្ឌសំដៅដោយផ្ទាល់ដល់ការចាត់ការសំណុំរឿងក្តីព្រហ្មទណ្ឌពោលគឺ របៀបរៀបចំដំណើរការនៃប្រព្រឹត្តកម្មរបស់សង្គមតបទៅនឹងអំពើ ឬភាពរឹករវដែលអាចចាត់ទុកថាជាបទល្មើស ។ នីតិវិធីព្រហ្មទណ្ឌ វាជាផ្នែកមួយនៃដំណើការតាមផ្លូវតុលាការ ។ ប៉ុន្តែនេះ មិនមែនជាដែនអនុវត្តតែមួយរបស់នីតិវិធីព្រហ្មទណ្ឌទេ ។ នីតិវិធីព្រហ្មទណ្ឌវាជាបណ្តុំនៃវិធាន ដែលកំណត់ពីបុគ្គលិក និងសកម្មភាពរបស់តុលាការ ព្រហ្មទណ្ឌចាប់តាំងពីពេលដែលមានការ សង្ស័យពីការប្រព្រឹត្តបទល្មើស រហូតដល់ពេលដែលវិត្រូវបានកំណត់អត្តសញ្ញាណ និងផ្តន្ទាទោស ។

នៅពេលដែលមានបទល្មើសមួយកើតឡើង គេសង្កេតឃើញមានកិច្ចនីតិវិធីជាច្រើនត្រូវបានអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ចស្របតាមវិធាននៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធ្វើការកំណត់អំពីអត្ថិភាពតាមផ្លូវច្បាប់នៃបទល្មើសនោះ មុនពេលដែលជនល្មើសត្រូវបានផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ។ ក្រមនីតិវិធីព្រហ្មទណ្ឌចែងដំណាក់កាលផ្សេងៗនៃដំណើរការនីតិវិធីដើម្បីកំណត់អំពីអត្ថិភាពនៃបទល្មើសដែលយើងអាចបែងចែកជាបីដំណាក់កាលនីតិវិធីធំៗ( នីតិវិធីនៃការចោទប្រកាន់នីតិវិធីនៃការស៊ើបសួរនិងនីតិវិធីជំនុំជម្រះ )។ យើងសង្កេតឃើញថានៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានផ្តល់នូវសិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរក្នុងកាតស្វែងរកភស្តុតាងដោះបន្ទុក និងដាក់បន្ទុក។ ទន្ទឹមនឹងនេះ ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់នៅសិទ្ធិអំណាចផ្តាច់មុខដល់ចៅក្រមស៊ើបសួរក្នុងការមានឆន្ទានុសិទ្ធិសម្រេចលើការឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ។ ការឃុំខ្លួនបណ្តោះអាសន្នជានីតិវិធីមួយដែលធ្វើឡើងនៅមុនពេលជម្រះក្តីក្នុងពេលដែលសំណុំរឿងព្រហ្មទណ្ឌស្ថិតនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសៀវភៅសារណានេះគឺបានលើកឡើងនូវប្រធានបទស្ដីពី **ការឃុំខ្លួនបណ្ដោះអាសន្នក្នុងដំណាក់កាលចៅក្រមស៊ើបសួរ** ដើម្បីយកមកពន្យល់បង្ហាញនិងរៀបរាប់អំពីនីតិវិធីនៃការឃុំខ្លួនបណ្ដោះ អាសន្ននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ លើសពីនេះទៅទៀតនៅពេលនិយាយអំពីការឃុំខ្លួនបណ្ដោះ អាសន្ន តែងតែមានសំនួរចោទសួរទៅលើប្រធានបទមួយនេះដូចជា៖

- តើការឃុំខ្លួនបណ្ដោះអាសន្នកើតមាននៅពេលណា ? ដើម្បីអ្វី ?
- តើមានមូលហេតុ ឬ លក្ខខណ្ឌអ្វីខ្លះក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ?
- តើលំហូរនីតិវិធីក្នុងការឃុំខ្លួនបណ្ដោះអាសន្នមានដូចម្ដេចខ្លះ ?
- តើជនត្រូវចោទមានសិទ្ធិអ្វីខ្លះក្នុងការឃុំខ្លួនបណ្ដោះអាសន្ននេះ ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាទៅលើប្រធានបទមួយនេះដោយសារតែ យើងខ្ញុំចង់ស្វែងយល់បន្ថែមឲកាន់តែច្បាស់អំពីការគោរព និងធានាឲបាននៅនីត្យានុកូលភាពនៃការឃុំខ្លួនបណ្ដោះអាសន្ន ។ បន្ថែមពីនេះស្វែងយល់ឲបានត្រឹមត្រូវនូវដំណើរការនៃនីតិវិធីឃុំខ្លួនបណ្ដោះអាសន្ន ក៏ដូចជាការអនុវត្តដីកានានានៅក្នុងនីតិវិធីនេះ។ លើសពីនេះទៅទៀត យើងខ្ញុំមានគោលដៅចម្បងក្នុងការលើកស្ទួយលើការអនុវត្តច្បាប់ព្រមទាំងចូលរួមផ្សព្វផ្សាយ និងជំរុញដល់ការស្រាវជ្រាវផ្នែកច្បាប់ឲកាន់តែមានវិសាលភាព។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ យើងខ្ញុំទាំងពីរបានស្វះស្វែងរក និងសិក្សាស្រាវជ្រាវច្បាប់បទដ្ឋានគតិយុត្តនានា តែចំពោះការឃុំខ្លួនបណ្ដោះអាសន្នដំណាក់កាលចៅក្រមស៊ើបសួរស្ថិតក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ក្រោយពីបានធ្វើការស្រាវជ្រាវសិក្សាទៅលើប្រធានបទស្ដីពី ការឃុំខ្លួនបណ្ដោះអាសន្នដំណាក់កាលចៅក្រមស៊ើបសួរ នាំឲយើងខ្ញុំទាំងពីរទទួលបាននូវចំណេះដឹងនូវប្រធានបទនេះយ៉ាងជាក់ច្បាស់ថា ការស្វែងយល់ពីប្រធានបទនេះពិតជាមានសារៈប្រយោជន៍ជាច្រើន។ បន្ទាប់ពីយើងខ្ញុំទាំងពីបានសិក្សារៀនសូត្រពីមុខជំនាញនីតិសាស្ត្រអស់រយៈពេល ៤ ឆ្នាំមកមុខវិជ្ជាដែលយើងខ្ញុំមានចំណាប់អារម្មណ៍និងចង់សិក្សាស្វែងយល់នោះគឺជានីតិវិធីព្រហ្មទណ្ឌ។ ម៉្យាងវិញទៀតយើងខ្ញុំទាំងពីរពេញចិត្តទៅលើប្រធានខាងលើនេះដោយ សារតែ

ប្រធានបទនេះមានសារៈសំខាន់ជួយឲពួកខ្ញុំយល់ដឹងបន្ថែមអំពីការឃុំខ្លួនបណ្តោះអាសន្នក៏ដូចជានីតិវិធីក្នុងការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទក្នុងដំណាក់កាលចៅក្រមស៊ើបសួរឲកាន់តែយល់ច្បាស់ជាងមុនទៅទៀយ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះដំណើរការនៃការស្រាវជ្រាវនេះផងដែរ យើងខ្ញុំទាំងពីបានធ្វើការស្វែងរកឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទខាងលើនេះតាម ការសាកសួរទៅលោកគ្រូសាស្ត្រាចារ្យ លោកមេធាវី ក៏ដូចជាបទដ្ឋានគតិយុត្តនានាដូចជា រដ្ឋធម្មនុញ្ញកម្ពុជា ក្រមព្រហ្មទណ្ឌកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ច្បាប់ផ្សេងទៀត ព្រមទាំងបទដ្ឋានគតិយុត្តអន្តរជាតិមួយចំនួនដូចជា សេចក្តីប្រកាស សេចក្តីថ្លែងការណ៍។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

មុននឹងឈានទៅដល់ការបកស្រាយទៅលើប្រធានបទមួយនេះ យើងខ្ញុំសូមធ្វើការប្រកាសប្លង់សារណាបញ្ចប់ការសិក្សានេះជាមុនសិន។ ប្លង់នៃសៀវភៅសារណាមួយក្បាលនេះចែកចេញជា 2ជំពូកធំៗ ៖

**ជំពូកទី១** និយាយអំពីសញ្ញាណទូទៅ គោលការណ៍នានា ព្រមទាំងលក្ខខណ្ឌ ថិរវេលានៃការឃុំខ្លួន និងមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន។

**ជំពូកទី២** និយាយអំពីដំណើរការនៃនីតិវិធីសម្រេចដាក់ឲឃុំខ្លួនបណ្តោះអាសន្នទាំងនីតិជនក្តី ឬ អនីតិជនក្តី។ ការចេញដីកានានាពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្តោះដោយចៅក្រមស៊ើបសួរ ក៏ដូចជាការសម្រេចដាក់ឲឃុំខ្លួន ព្រមទាំងសិទ្ធិរបស់ជនត្រូវចោទ។ បន្ថែមពីនេះជំពូកនេះផងដែរ ក៏បាននិយាយអំពីការដោះលែងឲនៅក្រៅឃុំ ក៏ដូចជាការដាក់ឲស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការផងដែរ។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមថា សៀវភៅសារណាដែលរៀបរាប់អំពី ការឃុំខ្លួនបណ្តោះអាសន្នដំណាក់កាលចៅក្រមស៊ើបសួរ មួយក្បាលនេះជាចំណែកមួយឲអ្នកអានសិស្ស និស្សិត ឬសិស្សជំនាន់ក្រោយបានដឹងនឹងទុកជាឯកសារស្រាវជ្រាវអំពីនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន និងការអនុវត្តជាក់ស្តែងក្នុងដំណាក់កាលនេះឲកាន់តែច្បាស់ ជាងនេះ។

# ជំពូកទី១៖
# គោលការណ៍ និង
# ការឃុំខ្លួនបណ្តោះអាសន្ន

# ជំពូកទី១

# គោលការណ៍ និងការឃុំខ្លួនបណ្តោះអាសន្ន

## ១.១ សញ្ញាណ និងគោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្ន គឺជានីតិវិធីមួយដែលធ្វើឡើងនៅមុនពេលជម្រះក្តី ក្នុងពេលដែលសំណុំរឿងព្រហ្មទណ្ឌស្ថិតនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរដើម្បីធានាមិនអោយអវត្តមានរបស់ជនជាប់ចោទនៅចំពោះ មុខតុលាការក៏ដូចជាការបង្កាមិនអោយមានការរំខានដល់ដំណើរការនៃការស៊ើបអង្កេត ឬទប់ស្កាត់ការប្រព្រឹត្តថ្មីទៀតមុនពេលជម្រះក្តី ។

### ១.១.១ សញ្ញាណទូទៅ

ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់នូវអំណាចទៅដល់ចៅក្រមស៊ើបសួរ ការផ្តល់អំណាចនេះគឺដើម្បីរក្សាជនត្រូវចោទឲស្ថិតនៅក្រោមការចាត់ចែងរបស់តុលាការ។ វិធានពីរយ៉ាងដែលចៅក្រមស៊ើបសួរយកមកប្រើប្រាស់ គឺការសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ឲស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។

### ១.១.២ គោលការណ៍សេរីភាព

ជនគ្រប់រូបមានសិទ្ធិរស់រៀនមានជីវិត មានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ប៉ុន្តែអ្វីដែលគួរឲយើងម្នាក់ៗគួរតែត្រូវដឹងចងចាំក្នុងចិត្ត និងជាការប្រតិបត្តិនោះគឺការរស់រៀន និងសេរីភាពរបស់មនុស្សគ្រប់រូបត្រូវធ្វើយ៉ាងណា កុំឲមានការប៉ះពាល់ដល់ការរស់នៅ និងសេរីភាពរបស់បុគ្គលផ្សេងទៀត។

**អ្វីទៅជាសេរីភាព?**

**សេរីភាព** ជាសិទ្ធិនៃកម្មសិទ្ធិរបស់មនុស្សម្នាក់ៗ ដែលមិនអាចដកហូតបាន[1]។ ប៉ុន្តែទទឹមនឹងនេះ ការប្រើប្រាស់សេរីភាពរបស់ខ្លួន មនុស្សត្រូវគោរពសិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់អ្នកដទៃ ក្នុងគោលបំណងឲមានសុខសន្តិភាព និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងសង្គម។ បើតាមសេចក្តី **ប្រកាសអំពីសិទ្ធិមនុស្សនៅឆ្នាំ១៧៨៩ របស់ប្រទេសបារាំង** បានឲ្យនិយមន័យសេរីភាពថាជា អំណាច ឬសិទ្ធិក្នុងការបំពេញសកម្មភាពអ្វីមួយ ដែលមិនធ្វើឲ្យខូចខាតដល់ប្រយោជន៍អ្នកដទៃ[2]។ **បើតាមវចនានុក្រមខ្មែរ** សេរីភាព មានន័យថាអំណាច ដែលអាចធ្វើអ្វី

[1] វ៉ាន់ ច័ន្ទតារា, នីតិសិទ្ធមនុស្ស Human Right Law (ភ្នំពេញ, បោះពពុម្ភ ឆ្នាំ២០១៤) , ទំព័រលេខ៦។

[2] សេចក្តីប្រកាសអំពីសិទ្ធមនុស្សប្រទេសបារាំង, ឆ្នាំ១៧៨៩។

បានតាម អំពើចិត្ត ប៉ុន្តែស្ថិតក្រោមច្បាប់។ ឯលោក កាល់ម៉ាក់ បានពោលថា សេរីភាពគឺជាការទទួលស្គាល់ការគោរព និងការបំពេញដោយម្ចាត់ចត់នូវតួនាទី និងភារកិច្ចរបស់ខ្លួន ។ ដូចនេះសេរីភាពគឺជាអំណាចក្នុងការធ្វើអ្វីបានកុំឲ្យតែប៉ះពាល់ដល់សិទ្ធិអ្នកដទៃ។ តាមន័យនេះសេរីភាពសម្គាល់បាននូវភាពធ្វើអ្វីៗ បានតាមចិត្តដោយគ្មានការបង្ខិតបង្ខំ ទោះបីក្នុង គំនិតក្តី ជំនឿក្តី និងសកម្មភាពសព្វបែបយ៉ាងក្តី អាចធ្វើបានតាមចិត្ត ឲ្យតែស្ថិតក្នុងក្របខ័ណ្ឌច្បាប់កំណត់ ។

ហេតុនេះហើយទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចដល់ចៅក្រមស៊ើបសួរ ក្នុងការសម្រេចឃុំខ្លួនជនត្រូវចោទយ៉ាងណាក៏ដោយ ជាគោលការណ៍ជនត្រូវចោទត្រូវមានសេរីភាព ក្នុងករណីពិសេសជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន ទៅតាមលក្ខខណ្ឌដែលមានចែងនៅផ្នែកនេះ ( ផ្នែកទី៥ ជំពូកទី៣ មាតិកាទី១ គន្លឹទី៤ ស្តីពីការឃុំខ្លួនបណ្តោះអាសន្នស្ថិតនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចាប់ពីមាត្រា២០៣ ដល់២១៨ )[3]។ ពោលគឺគ្មានជនណាម្នាក់ត្រូវបានដកហូតសេរីភាពនោះទេ លើកលែងតែមានហេតុផលច្បាស់លាស់ស្របទៅតាមនីតិវិធីដែលមានចែងក្នុងច្បាប់។

យ៉ាងណាមិញទោះជាចៅក្រមមានសិទ្ធិអំណាចក្នុងការសម្រេចដាក់ឲឃុំខ្លួនក៏ដោយ ប៉ុន្តែការប្រើនូវសិទ្ធអំណាចនេះចៅក្រមត្រូវធ្វើការវិនិច្ឆ័យក៏ដូចជាពិចារណាអោយបានម៉តចត់ ដើម្បីឲមានតុល្យភាពរវាងការឃុំខ្លួនបណ្តោះអាសន្ន និងសេរីភាពរបស់ជនត្រូវចោទផងដែរ។ ម្យ៉ាងទៀតជនត្រូវចោទបាត់បង់តែសិទ្ធិសេរីភាពតែប៉ុណ្ណោះ សិទ្ធិផ្សេងទៀតមិនត្រូវបានដកហូតនោះទេដូចជាសិទ្ធិការពារខ្លួនតាមផ្លូវតុលាការសិទ្ធិទទួលបានការជំនុំជម្រះដោយ យុត្តិធម៌ជាដើម[4]។

### ១.១.៣ គោលការណ៍សន្មតទុកជាមុនថាគ្មានទោស

**ការសន្មតជាមុនថាគ្មានទោស** (**Presumption of innocent**)“ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានសន្មតជាមុនថាជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ [5] ។

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២០៣។

[4] សន្និសិទស្តីពីការណែនាំពីការអនុវត្តដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៥-២៦ ខែមីនា ឆ្នាំ២០១៤ ទំព័រ៣៥, ៣៦ និង៣៧។

[5] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធមនុស្ស, ១០ ធ្នូ ១៩៤៨, មាត្រា១១ កថាខណ្ឌទី១។កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤ កថាខណ្ឌទី ២, ចុះថ្ងៃទី២៦ ឧសភា ឆ្នាំ១៩៤៨។

ធាតុផ្សំជាមូលដ្ឋានមួយនៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ គឺបុគ្គលគ្រប់រូបគួរតែត្រូវបានសន្មតថាគ្មានទោសលើកលែងតែ និងរហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញដោយការជំនុំជម្រះប្រកប ដោយយុត្តិធម៌មួយ ។ នេះជាមូលហេតុដែលទំនួលខុសត្រូវត្រូវបានធ្លាក់ទៅលើរដ្ឋក្នុងការបញ្ជាក់ពីពិរុទ្ធភាព និងធ្វើការដោះលែងឱ្យរួចខ្លួនស្របតាមការសម្មត់ថាគ្មានទោស។

យោងទៅតាមគោលការណ៍នៃការសម្មត់ថាគ្មានទោស នេះបុគ្គលមួយរូបមិនអាចត្រូវបានគេបង្ខិតបង្ខំអោយធ្វើការសារភាពពីពិរុទ្ធភាព ឬផ្តល់នូវភស្តុតាងប្រឆាំងនឹងខ្លួនឯងឡើយ។ វាគឺជាទំនួលខុសត្រូវរបស់រដ្ឋក្នុងការស្វែងរកភស្តុតាងបញ្ជាក់ពីពិរុទ្ធភាពនេះ ពោលគឺមិនមែនជាទំនួលខុសត្រូវរបស់ជនជាប់ចោទក្នុងការបញ្ជាក់ពីភាពស្អាត់ស្អំរបស់ខ្លួនទេ ។ ហេតុដូច្នេះហើយបានជាជាទូទៅ ការរក្សាភាពស្ងៀមស្ងាត់របស់ជនសង្ស័យមិនត្រូវបានប្រើប្រាស់ជាភស្តុតាងនៃពិរុទ្ធភាពទេ[6] ។

ដោយសារតែលទ្ធផលធ្ងន់ធ្ងរនៃការផ្តន្ទាទោសរដ្ឋត្រូវតែ បញ្ជាក់ពីពិរុទ្ធភាពក្នុងកម្រិតមួយខ្ពស់។ ប្រសិនបើនៅមានការសង្ស័យ ជនជាប់ចោទត្រូវទទួលបានផលប្រយោជន៍ពីវិមតិសង្ស័យនេះ និងត្រូវបានរួចផុតពីការចោទប្រកាន់ដោយហេតុថាបន្ទុកភស្តុតាងរបស់រដ្ឋមិនត្រូវបានបំពេញ។

ដោយផលប៉ះពាល់នៃនីតិវិធីព្រហ្មទណ្ឌមានសភាពធ្ងន់ធ្ងរទៅលើជនជាប់ចោទ រួមនឹងគោលការណ៍នៃការសន្មតថាគ្មានទោសផង ការជំនុំជម្រះគួរតែត្រូវបានធ្វើឡើងដោយគ្មានការពន្យាពេលដែលមិនសមស្របណាមួយនោះឡើយ ។ វានឹងមិនយុត្តិធម៌ទេក្នុងការផ្តល់ឱ្យរដ្ឋនូវឱកាសច្រើនដង ក្នុងការធានាឱ្យបាននូវការផ្តន្ទាទោស។ ប្រសិនបើរឿងក្តីមួយត្រូវបានធ្វើការជំមុំជម្រះហើយ ពិរុទ្ធភាពមិនត្រូវបានរកឃើញនោះទេ វាលែងតែមានអត្ថិភាពនៃករណីអញ្ញត្រកម្មណាមួយ បុគ្គលនោះមិនត្រូវបានគេជំនុំជម្រះម្តងទៀតនោះឡើយ។ ការនេះតម្រូវឱ្យរដ្ឋធ្វើកិច្ចការអយ្យការឱ្យបានសមស្របនៅក្នុងការជំនុំជម្រះលើកដំបូង។

គោលការណ៍នៃការសន្មតថាគ្មានទោស គឺជាមូលហេតុដែល មុនពេលដែលមានការផ្តន្ទាទោស ការិតត្បិតណាមួយទៅលើសិទ្ធិជាមូលដ្ឋានរបស់ជនសង្ស័យ ដូចជាសិទ្ធិទទួលបានសេរីភាព អាចត្រូវបានធ្វើឡើងតែក្នុងករណីចាំបាច់តែប៉ុណ្ណោះ។ បុគ្គលដែលកំពុងរងចាំការជំនុំជម្រះ ដែលមិនទាន់ត្រូវបានផ្តន្ទាទោសពីបទ

[6] Presumption of innocence បកប្រែដោយ Cambodia Law insider ចុះថ្ងៃទី 18 មេសា ២០២១ ។

ល្មើសណាមួយ និងក្នុងឆន្ទៈជាច្រើននឹងត្រូវរួចផុតពីការចោទប្រកាន់នៅទីបំផុត។ ព្រោះថា ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ[7]។

## ១.២ លក្ខខណ្ឌចាំបាច់ក្នុងការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នគឺ ជានីតិវិធីមួយដែលធ្វើឡើងនៅមុនពេលជម្រះក្តី ក្នុងពេលដែលសំណុំរឿងព្រហ្មទណ្ឌស្ថិតនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ ។ ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងបានក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ ឡើងទៅ[8] ។ ក៏ប៉ុន្តែការឃុំខ្លួនបណ្តោះអាសន្ន គឺប៉ះពាល់ដល់គោលការណ៍សេរីភាព[9] ជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព តែដើម្បីជាការងាយស្រួលក្នុងការដំណើរការនីតិវិធី របស់តុលាការអាចសម្រេចឃុំខ្លួនជនត្រូវចោទ។ ហើយការឃុំខ្លួននេះ មិនមែនចាត់ទុកថាជននោះមានទោសព្រហ្មទណ្ឌណាមួយនោះទេ តែជាការឃុំខ្លួនបណ្តោះអាសន្នដើម្បីទុកពេលឱ្យតុលាការស្វែងរកថា ជននោះមានទោសដែរ ឬ ទេតែប៉ុណ្ណោះ។

ការឃុំខ្លួនបណ្តោះអាសន្នជាជម្រើសចុងក្រោយ នឹងចាំបាច់ហេតុដូច្នេះហើយចៅក្រមស៊ើបសួរត្រូវពិចារណាឲ្យបានច្បាស់លាស់ អំពីលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្នដែលរួមមាន ***២.១ លក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទ ២.២ លក្ខខណ្ឌនៃទោសដែលត្រូវដាក់ពន្ធនាគា ២.៣ លក្ខខណ្ឌនៃអាយុរបស់ជនត្រូវចោទ។***

### ១.២.១ លក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទ

គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ គឺជានីតិវិធីព្រហ្មទណ្ឌមួយដែលផ្តល់សិទ្ធិអំណាចដល់ព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងអំពីចំណាត់ការទៅលើពាក្យប្តឹង និងពាក្យបណ្តឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលបញ្ជូនមក និងសម្រេចថាតើគួរតែតម្កល់រឿងទុកឥតចាត់ការ ឬគួរធ្វើការចោទប្រកាន់ទៅលើជនណាម្នាក់ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ[10] ។

[7] រដ្ឋធម្មនុញ្ញ,២៤ កញ្ញា ១៩៩៣,មាត្រា ៣៨ ។

[8] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៤ ។

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៣ ។

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា៤០ ។

ដោយព្រះរាជអាជ្ញាអាចប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចមិនធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌណាមួយ ទោះបីជាអំពើនោះមានចែងក្នុងក្រមព្រហ្មទណ្ឌ ឬច្បាប់ផ្សេងៗទៀតក៏ដោយ។ ជាគោលការណ៍ព្រះរាជអាជ្ញាអាចពិចារណាអំពីតុល្យភាពនៃការផ្តន្ទាទោស និងទំហំនៃព្យសនកម្ម (ការខូចខាត) របស់ជនរងគ្រោះ និងសង្គមជាតិទាំងមូលត្រូវទទួលរង ។

ប៉ុន្តែករណីមួយចំនួន ប្រសិនបើការសម្រេចតម្កល់រឿងទុកឥតចាត់ការ ត្រូវបានសម្រេចដោយព្រះរាជអាជ្ញា ដោយមិនបានពិចារណាថ្លឹងថ្លែងច្បាស់លាស់ទេក៏អាចជះនូវភាពអវិជ្ជមានផងដែរ។ ទើបក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថាប្រសិនបើអ្នកប្តឹងមិនសុខចិត្ត នឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការទេសាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន[11] ។ ប្រសិនបើយល់ឃើញថាការប្តឹងតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចេញអធិបញ្ជាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់។

យោងតាមខ្លឹមសារនៃក្រមនីតិវិធីព្រហ្មទណ្ឌ ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែក្នុងករណីត្រូវបានចោទប្រកាន់ ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម មានន័យថាលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើបានតែក្នុងករណីនៃការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមតែប៉ុណ្ណោះពោលគឺមិនអាចអនុវត្តបាននៅក្នុងករណីបទលហុនោះទេ [12] ។ ការចោទប្រកាន់នេះសំដៅទៅលើការចោទប្រកាន់ដែលធ្វើឡើងដោយអង្គការអយ្យការអមសាលាដំបូងដែលមានសមត្ថកិច្ច ។

### ១.២.២ លក្ខខណ្ឌនៃទោសដែលត្រូវដាក់ពន្ធនាគារ

ជាគោលការណ៍ការឃុំខ្លួនបណ្តោះអាសន្ន អាចអនុវត្តក្នុងករណីដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១(មួយ) ឆ្នាំ[13]។ ចំណុចនេះបានបញ្ជាក់អំពីគោលការណ៍ដែលច្បាប់បានកំណត់ចំពោះការឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមអាចធ្វើទៅបាន លុះត្រាតែបទល្មើសដែលត្រូវចោទប្រកាន់មិនមែនជាបទលហុ ដែលត្រូវជាបទមជ្ឈិម ឬ បទឧក្រិដ្ឋ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ មិនមែនត្រឹមជាទោសពិន័យជាប្រាក់ឡើយ ។

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា៤១, កថាខណ្ឌទី៤ និងទី៦។

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៤។

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៤ ។

នៅពេលចៅក្រមស៊ើបសួរវាយតម្លៃបានពីភស្តុតាងដែលជនត្រូវចោទ នឹងប្រឈមលើការផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១(មួយ) ឆ្នាំឡើងទៅក្នុងសំណុំរឿងដែលខ្លួនទទួលបាន និងត្រូវពិចារណាអំពីការសម្រេចដាក់ឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទ ។ តាមខ្លឹមសារនៃមាត្រានេះមានន័យថាជាទោសដែលច្បាប់កំណត់សម្រាប់បទល្មើសនីមួយៗ មិនមែនទោសដែលត្រូវប្រកាសដោយសាលក្រមនោះទេ ។

### ១.២.៣ លក្ខខណ្ឌនៃអាយុរបស់ជនត្រូវចោទ

អាយុរបស់ជនត្រូវចោទ ដែលសំដៅដល់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ[14] ។ ក្នុងករណីបើមានអនីតិជន ដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំប្រព្រឹត្តបទល្មើស ព្រហ្មទណ្ឌ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជន នោះបានតែចំពោះអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ រួមទាំងកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ[15] ។ ចំណែកឯអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ច្បាប់មិនតម្រូវឱ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ។

ទោះបីជាអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្ន និងចៅក្រមស៊ើបសួរត្រូវប្រគល់អនីតិជននោះទៅឱ្យឪពុកម្តាយ ឬអ្នកអាណាព្យាបាលវិញក៏ដោយ[16] ។ ក៏ប៉ុន្តែឪពុកម្តាយ ឬអ្នកអាណាព្យាបាល របស់អនីតិជនអាយុក្រោម ១៤ (ដប់បួន) នោះត្រូវទទួលខុសត្រូវសំណងព្យសនកម្មដែលអនីតិជនបានប្រព្រឹត្តឡើង។

## ១.៣. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ក្នុងករណីចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន គឺត្រូវស្ថិតក្នុងថិរវេលាដែលបានកំណត់ដោយច្បាប់យ៉ាងជាក់ លក្ខណ៍ទុកជាមុន ។ ហើយថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នគឺ ប្រែប្រួលទៅតាមប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអាយុរបស់ជនត្រូវចោទនោះជានីតិជន ឬ អនីតិជន។

[14] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា៣៨ ។

[15] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា៣៩ ។

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២១២ ។

### ១.៣.១ ថិរវេលាឃុំខ្លួន នីតិជន

ក្នុងករណីបទល្មើសព្រហ្មទណ្ឌណាមួយបានកើតឡើងដោយ នីតិជនហើយត្រូវបានដាក់ឱ្យឃុំខ្លួនបណ្តោះអាសន្ននោះថេរវេលានៃការឃុំខ្លួនជនត្រូវចោទគឺផ្អែកទៅលើចំណាត់ថ្នាក់នៃបទល្មើសថាបទល្មើសនោះជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិម ។

#### ១.៣.១.១ ថិរវេលាឃុំខ្លួន នីតិជនក្នុងបទឧក្រិដ្ឋ

ជាគោលការណ៍ច្បាប់ នីតិជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេ ។ ចៅក្រមស៊ើបសួរអាចធ្វើ ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទម្តងបាន ៦(ប្រាំមួយ)ខែហើយការឃុំខ្លួនបណ្តោះអាសន្ននេះអាចពន្យាបានចំនួន២(ពីរ)ដង[17] ។ ហើយការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះត្រូវធ្វើឡើង ដោយនីតិវិធីដេញដោលចំពោះមុខដូចនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្នដែរ[18] ។

#### ១.៣.១.២ ថិរវេលាឃុំខ្លួន នីតិជនក្នុងបទមជ្ឈិម

ក្នុងករណីបទមជ្ឈិមវិញ ចំពោះនីតិជនដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេ ។ ប៉ុន្តែ នៅពេលផុតថេរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នជននោះបានតែម្តងគត់ និងថេរវេលានៃការឃុំខ្លួននេះមិនឱ្យលើសពី ២(ពីរ)ខែ នោះទេ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។ ហើយមិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់កំណត់បានឡើយ[19] ។

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៨ ។

[18] ជួន សុភាសី, នីតិវិធីសង្ខេប: រដ្ឋប្បវេណី និងព្រហ្មទណ្ឌ, ឯកសារចម្លង ២០១១។

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៩ ។

**តារាងបង្ហាញពីថេរវេលាអតិបរមានៃការឃុំខ្លួនបណ្ដោះអាសន្ន សម្រាប់ប្រភេទបទល្មើសនីមួយៗ នៃរឿងក្ដី៖**

| *ប្រភេទនៃបទល្មើស និងមាត្រានីមួយៗនៃក្រមនីតិវិធីពាក់ព័ន្ធ* | *អាយុជនត្រូវចោទ* | *ថិរវេលាអតិបរមាដំបូងនៃការឃុំខ្លួន* | *ការពន្យាថិរវេលាឃុំខ្លួនតាមរយៈដីកាឃុំខ្លួនមួយទៀត* |
|---|---|---|---|
| បទឧក្រិដ្ឋ-មាត្រា២០៨ | ចាប់ពី ១៨ ឆ្នាំ ឡើងទៅ | ៦ ខែ | ៦ខែ + ៦ខែ |
| បទមជ្ឈិម-មាត្រា២០៩ | ចាប់ពី ១៨ ឆ្នាំ ឡើងទៅ | ៤ ខែ | ២ខែ<br>-ថេរវេលាសរុបមិនត្រូវលើសពីពាក់កណ្ដាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។ |

### ១.៣.២ ថិរវេលាឃុំខ្លួន អនីតិជន

អនីតិជន គឺជាជនដែលមានអាយុក្រោម ១៨ឆ្នាំ ហើយនីតិភាពនៃការទទួលខុស ត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ[20] ។

ក៏ប៉ុន្តែមិនមែនមាន ន័យថាគ្រប់អនីតិជនទាំងអស់សុទ្ធតែរួចផុតពីការទទួលខុស ត្រូវព្រហ្មទណ្ឌនោះទេ តុលាការ អាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌ ទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ។ ក៏ប៉ុន្តែក្នុងករណីអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី) ឆ្នាំ ត្រូវបានសម្រាចផ្តន្ទាទោសព្រហ្មទណ្ឌ គឺត្រូវបានបន្ថយអតិបរមានៃទោសពាក់កណ្ដាល ទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់[21] ។

ហេតុនេះហើយក្នុងករណីបទល្មើសព្រហ្មទណ្ឌ ណាមួយបានកើតឡើងដោយអនីតិជនចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅដែលតម្រូវឱ្យមានការឃុំខ្លួនបណ្ដោះអាសន្ន នោះថេរវេលានៃការឃុំខ្លួនជនត្រូវចោទគឺផ្អែកទៅលើចំណាត់ ថ្នាក់នៃបទល្មើសថាបទល្មើសនោះជាបទឧក្រិដ្ឋ ឬ ជាបទមជ្ឈិម ។ ដោយការឃុំខ្លួនបណ្ដោះ

[20] ច្បាប់ស្តីពីយុត្តធម៌អនីតិជន,លេខ នស/រកម/០៧១៦/០០៩,២៩ មិថុនា ២០១៦,មាត្រា៧ ។

[21] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា១៦០ ។

អាសន្ន ចំពោះអនីតិជនអនីតិជនមិនអាចធ្វើការពន្យារបាននោះទេទោះបីត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬជាបទមជ្ឈិមក៏ដោយ។

ហើយអនីតិជន ត្រូវបានបែងចែកជាពីរប្រភេទទៀតគឺ អនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ និងអនីតិជនមានអាយុចាប់ពី អាយុ១៦ ដល់ក្រោម ១៨ ឆ្នាំ ។

### ១.៣.២.១ ថិរវេលាឃុំខ្លួន អនីតិជនក្នុងបទឧក្រិដ្ឋ

ក្នុងករណីបទឧក្រិដ្ឋអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំរហូតអាយុក្រោម ១៦ ឆ្នាំការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេ ។ ប្រសិនបើអនីតិជននោះមានអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ វិញការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេ[22] ។

### ១.៣.២.២ ថិរវេលាឃុំខ្លួន អនីតិជនក្នុងបទមជ្ឈិម

ក្នុងករណីបទមជ្ឈិម ការឃុំខ្លួនបណ្តោះអាសន្នអនីតិជនមិនអាចលើសពី ២ (ពីរ) ខែបានទេកាលណាអនីតិជននោះមានអាយុចាប់ពី ១៤ ឆ្នាំ រហូតដល់ក្រោម ១៦ ឆ្នាំ ។ សំរាប់អនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ការឃុំខ្លួនបណ្តោះអាសន្នមានរយៈពេលមិនអាចលើសពី ៤ (បួន) ខែបានទេ ។

បទមជ្ឈិម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់កំណត់ សម្រាប់អនីតិជនបានឡើយ[23] ។

---

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២១៣ ។

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២១៤ ។

**តារាងបង្ហាញពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្ន សម្រាប់ប្រភេទបទល្មើស នីមួយៗ នៃរឿងក្តី៖**

| *ប្រភេទនៃបទល្មើស និង មាត្រានីមួយៗនៃក្រម នីតិវិធីពាក់ព័ន្ធ* | *អាយុជនត្រូវចោទ* | *ថិរវេលាអតិបរមាដំបូង នៃការឃុំខ្លួន* | *ការពន្យាថិរវេលាឃុំខ្លួនតាមរយៈដីកាឃុំ ខ្លួនមួយទៀត* |
|---|---|---|---|
| បទឧក្រិដ្ឋ-មាត្រា២១៣ | អាយុ ១៤ ឆ្នាំដល់ ក្រោម ១៦ ឆ្នាំ | ៤ ខែ | មិនអាចពន្យាឃុំខ្លួនបានឡើយ |
| | ១៦ ឆ្នាំ ដល់ ក្រោម ១៨ ឆ្នាំ | ៦ ខែ | មិនអាចពន្យាឃុំខ្លួនបានឡើយ |
| បទមជ្ឈិម-មាត្រា២១៤ | អាយុ ១៤ ឆ្នាំដល់ ក្រោម ១៦ ឆ្នាំ | ២ ខែ ឬ ១/២ នៃអប្បបរមា នៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជន (ថិរវេលាមួយណាក៏បានដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំងពីរនេះ) | មិនអាចពន្យាឃុំខ្លួនបានឡើយ |
| | ១៦ ឆ្នាំ ដល់ ក្រោម ១៨ ឆ្នាំ | ៤ ខែ ឬ ១/២ នៃអប្បបរមា នៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជន(ថិរវេលាមួយណាក៏បានដែលថិរវេលាខ្លីបំផុតរវាងថិរវេលាទាំងពីរនេះ) | ២ ខែ<br>-ថិរវេលាសរុបមិនត្រូវលើសពីពាក់កណ្តាល អប្បបរមានៃទោស ដែលច្បាប់បានកំណត់ឡើយ |

## ១.៤. មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន

ក្រៅពីលក្ខខណ្ឌចាំបាច់ក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ដែលបានបកស្រាយខាងលើ ដើម្បីសម្រាប់ឃុំខ្លួនបណ្ដោះអាសន្នទៅលើជនត្រូវចោទ គឺតម្រូវឱ្យចៅក្រមស៊ើបសួរ ចេញដីការសម្រេចដោយបង្ហាញអំពីមូលហេតុចាំបាច់ ដែលតម្រូវឱ្យធ្វើការឃុំខ្លួនបណ្ដោះអាសន្នដោយបានចែងអំពី (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧[24] ។

### ១.៤.១ មូលហេតុទូទៅ

ក្នុងករណីការឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវបង្ហាញអំពីមូលហេតុមួយ ឬច្រើន ដោយលើកយកសម្អាងហេតុសម្រាប់គាំទ្រទៅ និងមូលហេតុណាមួយ ដែលចៅក្រមស៊ើបសួរបានលើកឡើង ឬមិនត្រូវយកមកអនុវត្តដែលមានជាអាទិ៍ដូចតទៅ[25] ។

#### ១. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី[26]

ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចបញ្ចប់ ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី -តើមានហេតុផលសមរម្យ ដើម្បីជឿជាក់ថាជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើសដែលខ្លួនត្រូវចោទ ឬទេ ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថាជនត្រូវចោទអាចបន្តប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសនោះជាថ្មីឬទេ[27] ?

ក្នុងករណីជនល្មើសត្រូវបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ណាមួយហើយត្រូវឃាត់ខ្លួននោះចៅក្រមស៊ើបសួរត្រូវពិនិត្យមើលលទ្ធភាពនៃការកើតឡើងវិញនៃបទល្មើស ឬការរាលដាលនៃបទល្មើសបន្តទៀត ព្រោះករណីខ្លះប្រសិនបើជនល្មើសមិនត្រូវបានឃុំខ្លួនទេនោះអាចនឹងមានលទ្ធភាពនៃការបន្តសកម្មភាពល្មើសទៀតបាន ដោយសាមានការគុំគួនទៅលើដើមចោទដែលបានដាក់ពាក្យបណ្ដឹង ។

ឧទាហរណ៍៖ បទល្មើសព្រហ្មទណ្ឌ ការលោភសេពសន្ថវៈ រួចគំរាមថា និងសម្លាប់ ប្រសិនបើជនរងគ្រោះហ៊ានប្ដឹងខ្លួនដែលជនរងគ្រោះបានមកដាក់ពាក្យបណ្ដឹង ហើយចៅក្រមស៊ើបសួរបានកោះហៅជនត្រូវចោទមកបំភ្លឺ។ បន្ទាប់មកចៅក្រមស៊ើបសួរមិនធ្វើការឃុំខ្លួនបណ្ដោះអាសន្ននោះទេដោយអនុញ្ញាតឱ្យជននោះនៅក្រៅ

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៦ កថាខណ្ឌទី២ ។
[25] សេចក្ដីណែនាំលេខ: ១២០កឃ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌។
[26] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៥ កថាខណ្ឌទី១ ។
[27] សេចក្ដីណែនាំលេខ: ១២០កឃ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ចំណុចទី៣គួច។

ឃុំនោះបទល្មើសអាច នឹងត្រូវបានកើតឡើងជាថ្មីដោយជនល្មើសព្យាយាមធ្វើការសងសឹងដោយធ្វើការសម្លាប់ទៅលើជនរងគ្រោះ ឬគ្រួសារជនរងគ្រោះ។

**២. ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត**[28]

ចៅក្រមស៊ើបសួរ ត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចរារាំងដល់ការគាបសង្កត់ សាក្សី ឬជនរងគ្រោះ ឬ រារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចគាបសង្កត់សាក្សី ឬជនរងគ្រោះដែរ ឬទេ? តើជនសមគំនិតនៅតែមានសេរីភាពដែរ ឬទេ (មិនបារម្ភពីការត្រូវរ៉ូវគ្នាទេ ប្រសិនបើពួកគេត្រូវបានឃុំខ្លួន)[29]?

ក្នុងករណីបទល្មើសព្រហ្មទណ្ឌមួយត្រូវបានកើតឡើងអាចមានជនល្មើសមួយ ឬច្រើននាក់អាចជា ចារី[30] សហចារី[31] និងអ្នកសមគំនិត[32] ជាដើម ។ ហើយសកម្មភាពនៃការប៉ុនប៉ងប្រព្រឹត្តបទល្មើសនោះអាចមានសាក្សីបានឃើញហេតុការណ៍ផ្ទាល់ភ្នែកហើយសក្ខីកម្មរបស់សាក្សីនេះឯងជាភស្តុតាងដ៏សំខាន់ដើម្បីបង្ហាញពីការពិតនៃអង្គហេតុទាំងមូល។

ក្នុងករណីក្រោយពេលជនត្រូវចោទចូលខ្លួនមកបំភ្លឺ ចៅក្រមស៊ើបសួរមិនធ្វើការឃុំខ្លួនបណ្តោះអាសន្ននោះទេដោយអនុញ្ញាតឱ្យជននោះនៅក្រៅឃុំនោះជនត្រូវចោទអាចទៅគំរាមគំហែងដល់ជនរងគ្រោះ ឬសាក្សីដើម្បីមិនឱ្យឆ្លើយការពិតនៅចំពោះមុខតុលាការ ។ ហើយជនត្រូវចោទ នឹងអ្នកសមគំនិតអាចត្រូវរ៉ូវគ្នាទៅបំផ្លាញភស្តុតាងផ្សេងៗ ដែលសមត្ថកិច្ចពុំទានបានរកឃើញ ។ ហេតុនេះហើយការឃុំខ្លួនបណ្តោះអាសន្នជាករណីចាំបាច់មួយដែលជួយសំរួលដល់នីតិវិធីតុលាការ។

ឧទាហរណ៍៖ ក្នុងករណីអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស[33] ដែលបង្កដោយជនសង្ស័យមួយក្រុមដែលជាសិស្សបានប្រើប្រាស់ដាវ និងដំបងវាយទៅលើជនរងគ្រោះម្នាក់ដែលជាសិស្សដូចគ្នាបណ្តាល

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៥ កថាខណ្ឌទី២ ។

[29] សេចក្តីណែនាំលេខ: ១២០កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ចំណុចទី៥គូច។

[30] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា២៥ ។

[31] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា២៦ ។

[32] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា២៩ ។

[33] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា២១៨ ។

ឱ្យមានរបួសធ្ងន់ ហើយមានសិស្សដទៃបានឃើញផ្ទាល់ភ្នែកនៅហេតុទាំងមូល។ ក្រោយពេលទទួលបានពាក្យបណ្តឹងសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យទាំងនោះដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើការសាកសួរ ក្រោយមកមិនបានសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទទាំងនោះទេ។ ហេតុនេះជនសង្ស័យទាំងនោះអាចត្រូវរ៉ូវគ្នាទៅគំរាមគំហែងជនរងគ្រោះ និងសាក្សី មិនឱ្យនិយាយពីការពិតនៅចំពោះមុខចៅក្រមស៊ើបសួរ ឬបំផ្លាញភស្តុតាងនាំឱ្យតុលាការពិបាកស្វែងរកការពិត ដើម្បីបង្ហាញពីពិរុទ្ធភាពរបស់ជនត្រូវចោទ ។

### ៣. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ[34]

ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបនៃការឃុំខ្លួន អាចរារាំងជនត្រូវចោទពីការធ្វើឱ្យខូចពីភស្តុតាង ឬតម្រុយជាសម្ភារៈ - តើនៅតែមានភស្តុតាង ឬ តម្រុយជាសម្ភារៈ ដែលនគរបាលមិនទាន់មានដែរ ឬទេ ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងគេចខ្លួន ឬបំផ្លាញភស្តុតាង ឬតម្រុយជាសម្ភារៈ ឬ អាវុធពាក់ពន្ធនឹងបទល្មើសជា ដើម[35] ?

ក្នុងបទល្មើសមួយភស្តុតាងគឺមិនមែនមានតែជនរងគ្រោះ និងសាក្សីដែលបានឃើញដោយផ្ទាល់នោះទេវាអាចមានភស្តុតាង ឬតម្រុយជាសម្ភារៈផ្សេងទៀតដែលអាចបញ្ជាក់ពីការពិតនៃអង្គហេតុ ។ ដោយចៅក្រមស៊ើបសួរ ជាអ្នកបំពេញកិច្ចស៊ើបសួរទាំងអស់ដែលយល់ឃើញថាមានប្រយោជន៍ទាំងដាក់បន្ទុក និងដោះបន្ទុក[36] ដើម្បីបញ្ជាក់ពីពិរុទ្ធភាពរបស់ជនត្រូវចោទថាមានដែរ ឬទេ ។ ប្រសិនបើភស្តុតាងត្រូវបានលុបបំបាត់ ការពិតមិនអាចរកឃើញបានឡើយ ហើយយុត្តិធម៌ក៏អាចបាត់បង់ទៅតាមនោះដែរហេតុនេះហើយ ទើបការឃុំខ្លួនបណ្តោះអាសន្នគឺជាករណីចាំបាច់ដើម្បីធានាថាជនត្រូវចោទ មិនអាចទៅបំផ្លាញភស្តុតាង ឬតម្រុយបញ្ជាក់ពីពិរុទ្ធភាពរបស់ខ្លួនបានឡើយ ។

ឧទាហរណ៍៖ បទល្មើសជួញដូរគ្រឿងញៀន[37] ចៅក្រមស៊ើបសួរត្រូវតែសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ដើម្បីការពារមិនឱ្យជនត្រូវចោទនោះ មានឱកាសទៅបំផ្លាញវត្ថុតាង ឬផ្តល់ដំណឹងទៅឱ្យប៉ាក់ពួកផ្លាស់ប្តូរទីតាំងរក្សាវត្ថុតាងគ្រឿងញៀនដែលសមត្ថកិច្ចមិនទាន់បានរកឃើញ ។ ហើយវត្ថុតាងនៅក្នុងករណីនៃ

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៥ កថាខណ្ឌទី៣ ។
[35] សេចក្តីណែនាំលេខ: ១២០កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ចំណុច គ ទំព័រទី៣។
[36] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១២៧ ។
[37] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, លេខ នស/រកម/០១១២/០០១, ២៥ វិច្ឆិកា ២០១១, មាត្រា៤០ ។

បទល្មើសគ្រឿងញៀនសំខាន់ណាស់ ព្រោះការសម្រេចទោសគឺផ្អែកលើបរិមាណសារធាតុសុទ្ធដែលមានចែងនៅក្នុងតារាងនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

### ៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី[38]

ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចធានារក្សាវត្តមានជនត្រូវ ចោទទុកជូនតុលាការចាត់ការតាមនីតិវិធី តើមានភាពសមរម្យដើម្បីជឿជាក់ថាជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬភៀសខ្លួនទៅក្រៅប្រទេសដែរ ឬទេ[39] ?

ក្រោយពីចៅក្រមស៊ើបសួរកោះហៅជនត្រូវចោទ និងដើមចោទមកដើម្បីធ្វើនីតិវិធីដេញដោលចំពោះមុខរួចចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជនត្រូវចោទដោយដាក់ឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន។ ក្នុងករណីជនត្រូវចោទគិតថាគ្មានផ្លូវ និងអាចរួចផុតពីការទទួលខុសត្រូវតាមផ្លូវច្បាប់នោះទេជនត្រូវចោទអាច និងប្រើប្រាស់វិធីរត់កិច្ចខ្លួនជាដើម។

ឧទាហរណ៍៖ ជនសង្ស័យម្នាក់ដែលត្រូវបានចោទពីបទលួច មានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ[40] ។ ដោយសារជនសង្ស័យនោះបានចូលលួចទ្រព្យសម្បត្តិក្នុងផ្ទះ អ្នកដទៃ ហើយត្រូវម្ចាស់ផ្ទះមកទាន់ ក៏មានការប្រតាយប្រតប់គ្នា ជនសង្ស័យបានទាញកាំបិតដែលនៅជិតនោះចាក់ត្រូវម្ចាស់ផ្ទះបណ្ដាលឱ្យស្លាប់រួចរត់គេចខ្លួន ។ បន្ទាប់មកសមត្ថកិច្ចធ្វើការឃាត់ខ្លួនជនសង្ស័យបាន រួចបញ្ជូនទៅឱ្យចៅក្រមស៊ើបសួរធ្វើការសាកសួរ ហើយចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជនត្រូវចោទដោយសម្រេចឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ។ នោះជនត្រូវចោទ និងអាចមានឱកាសរត់កិច្ចខ្លួនដើម្បីរួចផុតពីការទទួលខុសត្រូវតាមផ្លូវច្បាប់។

### ៥. ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ[41]

ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចការពារសន្តិសុខឱ្យជនត្រូវចោទ តើមានយោបល់ណាមួយដែលថាជនរងគ្រោះ ឬជនផ្សេងទៀតអាចបង្កគ្រោះថ្នាក់ដល់ជនត្រូវចោទ ដែរ ឬទេ[42] ?

---

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៥ កថាខណ្ឌទី៤ ។

[39] សេចក្ដីណែនាំលេខ: ១២០កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ចំណុច ឃ។

[40] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា៣៦០ ។

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៥ កថាខណ្ឌទី៥ ។

[42] សេចក្ដីណែនាំលេខ: ១២០កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ចំណុច ង។

ជាធម្មតាជនល្មើសតែងតែទទួលបានការស្អប់ខ្ពើម ដោយសារបានប្រព្រឹត្តអំពើដែលបង្ករព្យសនកម្មទៅដល់ ប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូល ។ ជាពិសេសសាច់ញាតិរបស់ជនរងគ្រោះ ឬអ្នកដែលបានឃើញហេតុការ តែងតែមានអារម្មណ៍ស្អប់ខ្ពើមនូវទង្វើដែលជនត្រូវចោទបានធ្វើដោយបន្សសទុកជា របួសស្នាម ប៉ះពាល់ដល់អាយុជីវិត ឬអំពើឃោឃៅផ្សេងៗ ។ នេះហើយជាដើមហេតុដែលនាំឱ្យសាច់ញាត និង អ្នកដែលបានឃើញហេតុការមានការគុំគួន និងមានគំនិតចង់សងសឹកមកលើជនត្រូវចោទក្រៅប្រព័ន្ធតុលាការដោយប្រើប្រាស់អំពើហឹង្សា ឬសម្លាប់ជនល្មើសតែម្តង។ ទោះបីជាក្រមព្រហ្មទណ្ឌ ចែងថាការសងសឹកក្រៅប្រព័ន្ធតុលាការជាអំពើដែលត្រូវបានហាមឃាត់ក៏ដោយ ប៉ុន្តែក្នុងសង្គមជាក់ស្តែង យើងតែងតែឃើញមានការសងសឹកទៅលើជនត្រូវចោទដោប្រើប្រាស់ហឹង្សាជដែល ។ ហេតុនេះហើយការឃុំខ្លួនជាបណ្តោះអាសន្ន គឺជាមធ្យោបាយចាំបាច់មួយក្នុងការរក្សាសុវត្ថិភាពជូនជនត្រូវចោទពីការធ្វើបាប ឬការសងសឹកពីសំណាក់ជនរងគ្រោះ ឬសាច់ញាតិជនរងគ្រោះជាដើម ។

ឧទាហរណ៍៖ លោក **ក** ប្រកបមុខរបរជាអ្នករត់តាក់ស៊ី ពីខេត្តកំពតទៅ ភ្នំពេញ ជារៀងរាល់ថ្ងៃមិនសូវមានអ្នកដំណើរជិះជាមួយគាត់ច្រើននោះទេ ។ គាប់ជួនថ្ងៃមួយមានភ្ញៀវតែម្នាក់គត់គឺលោកស្រី **ខ** ត្រូវធ្វើដំណើរទៅភ្នំពេញដោយជិះតាក់ស៊ីលោក **ក** លុះបើកដល់កន្លែងស្ងាត់លោក **ក** បានឈប់ឡានរួចចាប់រំលោភ ទៅលើលោកស្រី **ខ** បានសម្រេច។ បន្ទប់មកលោក **ក** ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនរួចបញ្ជូនទៅឱ្យតុលាការ ហើយត្រូវបានចោទពីបទបទរំលោភសេពសន្ថវៈ[43] តែចៅក្រមស៊ើបសួរ សម្រេចឱ្យលោក **ក** នៅក្រៅឃុំជាបណ្តោះអាសន្ន ដោយមើលឃើញថាលោក **ក** ជាជនក្រីក្រហើយមានម្តាយចាស់ជរា កំពុងឈឺធ្ងន់ដែលត្រូវការលោក **ក** មើលថែរក្សាជាចាំបាច់។ ក្នុងរយះពេលនៃការឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នប្តីលោកស្រី **ខ** ដែលកំពុងមានអារម្មណ៍គុំគួនទៅលើលោក **ក** បានទៅចាក់សម្លាប់លោក **ក** តែម្តងដើម្បីជាការសងសឹក ។ ហេតុនេះការឃុំខ្លួនជាបណ្តោះអាសន្ន គឺជាមធ្យោបាយដ៏ល្អមួយ ដើម្បីរក្សាសុវត្ថិភាពជូនជនត្រូវចោទពីការសងសឹកពីសំណាក់ជនរងគ្រោះ ឬសាច់ញាតិជនរងគ្រោះជាដើម។

[43] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា២៣៩ ។

**៦. ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស**[44]

ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនជនត្រូវចោទ អាចរក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានភាពច្របូកច្របល់ណាមួយដែលបណ្តាលមកពីបទល្មើស[45] ។

ជាធម្មតាព្យសនកម្មនៃបទល្មើសមិនដូចគ្នាទេបទល្មើសមួយចំនួនមានលក្ខណៈស្រាល និងបង្កព្យសនកម្មតិចតួច ទើបការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើការលើកលែងបាន ដោយអនុញ្ញាតឱ្យជននោះនៅក្រៅឃុំជាបណ្តោះអាសន្ន។ ក៏ប៉ុន្តែបទល្មើសខ្លះមានលក្ខណៈសាហាវឃោរឃៅ និងបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរបង្កឱ្យមានផលប៉ះពាល់ដល់សន្តិសុខសង្គម នាំឱ្យសង្គមជាតិមានភាពច្របូកច្របល់ ឬអាចនាំឱ្យមានការបាត់បង់អាយុជីវិតមនុស្សជាច្រើននាក់ ទើបបានជាការឃុំខ្លួនបណ្តោះអាសន្នត្រូវតែធ្វើភ្លាមៗ និងជាចាំបាច់បំផុត។

ឧទាហរណ៍៖ បទឧក្រិដ្ឋប្រល័យពូជសាសន៍[46] បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[47] បទឧក្រិដ្ឋសង្គ្រាម[48] អំពើក្បត់ជាតិ និងចារកម្ម[49] បទបង្កើតដោយខុសច្បាប់នូវកម្លាំងប្រដាប់អាវុធ[50]។

### ១.៤.២ មូលហេតុពិសេសផ្សេងទៀត

ក្រៅពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន និងមូលហេតុនៃការគេចវេះដោយចេតនារបស់ជនត្រូវចោទពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ[51] ដើម្បីការពារមិនឱ្យជនត្រូវចោទគេចវេះពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការដោយអនុញ្ញាត ឱ្យចៅក្រមស៊ើបសួរក្នុងការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទដែលជាមូលហេតុពិសេសនៃការឃុំខ្លួនបណ្តោះអាសន្ន ។

---

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២០៥ កថាខណ្ឌទី៦ ។

[45]សេចក្តីណែនាំលេខ: ១២០កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ចំណុច ច។

[46] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា១៨៣ ។

[47] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា១៨៨ ។

[48] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា១៩៣ ។

[49]ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា៤៣៩ ។

[50] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា៤៦៣ ។

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២៣០ ។

ច្បាប់ក៏បានចែងអំពីមូលហេតុផ្សេងទៀត ក្នុងករណីចៅក្រមស៊ើបសួរដាក់ជនត្រូវចោទឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ដោយប្រើប្រាស់ដីកាបង្គាប់ឱ្យដាក់ជនត្រូវចោទនោះស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។ វាអាចជាគំនិតរបស់ចៅក្រមស៊ើបសួរ ឬតាមសេចក្ដីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា ។ ហើយចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទឱ្យគោរពនូវកាតព្វកិច្ចមួយ ឬច្រើនដែលច្បាប់បាននិយាយអំពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ[52] ។

ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទ ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនោះត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារដោយអានុភាពបង្គាប់ឱ្យជនត្រូវចោទគោរពនូវកាតព្វកិច្ចមួយ ឬច្រើនដែលបានចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧[53] ។

ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ក្នុងករណីជនត្រូវចោទជាអនីតិជនមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំមិនអាចត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ[54] ។

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២២៦ ។

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២២៣ ។

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា២២៤ ។

# ជំពូកទី២៖
# នីតិវិធីស្តិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន

# ជំពូកទី២
# នីតិវិធីស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន

## ២.១ ដំណើរការនីតិវិធីសម្រេចដាក់ឲឃុំខ្លួនបណ្តោះអាសន្ន

ពិតណាស់ការសម្រេចដាក់ឲឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ គឺត្រូវអនុវត្តអោយបានត្រឹមត្រូវ និងត្រូវគោរពទៅតាមគោលការណ៍ទៅតាមនីតិវិធីដូចតទៅៈ

### ២.១.១ ការបង្ហាញខ្លួនលើកដំបូងនៃជនត្រូវចោទ

ជនត្រូវចោទត្រូវបង្ហាញខ្លួនលើដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ការបង្ហាញខ្លួនលើកដំបូងនេះត្រូវធ្វើឡើងដោយផ្អែកតាមមូលហេតុដូចតទៅៈ

- ការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំរបស់ព្រះរាជអាជ្ញាក្រោយពេលដែលជនត្រូវចោទត្រូវបានសមត្ថកិច្ចចាប់ខ្លួន
- តាមរយៈដីកាបង្គាប់អោយចូលខ្លួន, ដីកាបង្គាប់អោយនាំខ្លួន, ដីកាបង្គាប់អោយចាប់ខ្លួន។

ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហាតុមួយដែលកំណត់ហេតុនេះហៅថាកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង ។ ការធ្វើកំណត់ហេតុនេះឡើង ដើម្បីបំពេញកិច្ចមួយចំនួនខាងក្រោម ៖

ចៅក្រមត្រូវធ្វើការត្រួតពិនិត្យអត្តសញ្ញាណជនត្រូវចោទ ដែលត្រូវបង្ហាញមុខនៅចំពោះមុខការធ្វើបែបនេះ គឺដើម្បីជៀសវាងពីការភាន់ច្រឡំណាមួយដែលអាចកើតឡើងជាយថាហេតុ ។ បន្ថែមពីនេះគឺដើម្បី ផ្ទៀងផ្ទាត់លើអត្តសញ្ញាណជនដែលនាំមកបង្ហាញខ្លួនទៅនឹងអត្តសញ្ញាណដែលមាននៅក្នុងដីកាសន្និដ្ឋានអោយស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ។ ជាងនេះទៅទៀតដើម្បីត្រួតពិនិត្យថាជនដែលត្រូវចោទនោះជាអនីតិជន ឬយ៉ាងណា ។

ក្រោយពីពិនិត្យនឹងកំណត់អត្តសញ្ញាណរួចរាល់ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរីនិទ្ទេសស្តីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅក្នុងពេលចូលបង្ហាញខ្លួនជាលើកដំបូង។ ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។ ចៅក្រមស៊ើប

សួរត្រូវប្រាប់ជនត្រូវចោទ ឲបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឲចាត់តាំងមេធាវីអោយខ្លួនដោយអនុវត្តទៅតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី[55] ជនត្រូវចោទជាអនីតិជនត្រូវមានមេធាវីអមជានិច្ច។

ជនត្រូវចោទអាចស្តួរចម្លើយបានតែនៅចំពោះមុខមេធាវីប៉ុណ្ណោះលើកលែងតែមានករណីពិសេស ឬប្រសិន បើជនត្រូវចោទនេះបោះបង់សិទ្ធិរបស់ខ្លួនក្នុងការដែលត្រូវមានមេធាវី ។ ក្នុងប្រសិនបើការស្តួរចម្លើយជនត្រូវចោទត្រូវបានធ្វើឡើងដោយពុំមានវត្តមានមេធាវី កំណត់ចំណាំនៃការបោះបង់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៃការស្តួរចម្លើយជាលាយលក្ខណ៍អក្សរ ។[56]

បន្ទាប់ពីកិច្ចបង្ហាញខ្លួនលើកដំបូងត្រូវបានបញ្ចប់ ចៅក្រមស៊ើបសួរនឹងបើកកិច្ចពិភាក្សាដេញដោលចំពោះមុខមួយទៀតដើម្បីយកមកធ្វើជាមូលដ្ឋានគតិយុត្តអំពីការ សម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ។

### ១.១.២ កិច្ចនៃការពិភាក្សាដេញដោលចំពោះមុខ

កិច្ចពិភក្សាដោញដោលចំពោះមុខជានីតិវិធីមួយដែលធ្វើដើម្បីបង្ហាញឲឃើញនូវភាពយុត្តិធម៌ សមភាពរបស់ប្រព័ន្ធតុលាការទៅលើការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើសិទ្ធនិងសេរីភាពរបស់ជនត្រូវចោទ។ កិច្ចពិភាក្សាដេញដោលចំពោះមុខអំពីការឃុំខ្លួន ឬមិនឃុំជាកិច្ចការរបស់ចៅក្រមស៊ើបសួរក្នុងការស្តាប់ និងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ឬមិនឃុំហើយការសម្រេចកិច្ចនេះត្រូវចុះនៅក្នុងកំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ។

នៅក្នុងកិច្ចពិភាក្សាដេញដោលចំពោះមុខនេះផងដែរ ត្រូវធ្វើកំណត់ហេតុមួយដែលហៅថា កំណត់ហេតុស្តីពីការដេញដោលនៅចំពោះមុខ ។ កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ ត្រូវធ្វើបន្ទាប់ពីជនត្រូវចោទបាននាំយកមកបង្ហាញខ្លួន[57] ។ ចៅក្រមស៊ើបសួរត្រូវប្រាប់ ឬជូនដំណឹងដល់ជនត្រូវចោទពីការសម្រេចពីការឃុំខ្លួនដែលខ្លួនបានសម្រេចក្រោយពីកិច្ចពិភាក្សាដេញដោលបានបញ្ចប់[58] ។ ទាក់ទងទៅនឹងការពិភាក្សាដេញដោលនេះផងដែរជនត្រូវចោទមានសិទ្ធសេរីភាពទៅលើការឆ្លើយថា ខ្លួននឹងឆ្លើយ ឬ មិនឆ្លើយ ក្នុងអំឡុង

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា១៣៤។

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា១៤៥។

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២០៦។

[58] ជួន សុភាសី, “ នីតិវិធីសង្ខេបៈ រដ្ឋប្បវេណី និងព្រហ្មទណ្ឌ” (ឯកសារចម្លង,២០១១ )។

កិច្ចនេះ។ ប្រសិនបើជនត្រូវចោទឆ្លើយ ចៅក្រមស៊ើបសួរត្រូវទទួលនូវចម្លើយនោះភ្លាម។ ជនត្រូវចោទអាចរកមេធ្យោបាយអោយមេធាវីការពារសិទ្ធិអោយខ្លួននៅក្រៅឃុំបាន( បើមានមេធាវី ) ។ ចំពោះព្រះរាជអាជ្ញាដែលជាតំណាងអយ្យការក្នុងកិច្ចពិភាក្សាដេញដោលនេះអាចចូលរួម ឬមិនចូលរួមក៏បាន ។ ការដេញដោលសួរចម្លើយត្រូវធ្វើឡើងដោយចៅក្រមស៊ើបសួរ ទោះជាយ៉ាងនេះក្តីព្រះរាជអាជ្ញា និងមេធាវីដទៃទៀតក៏អាចសាកសួរបានដែរដោយមានការអនុញ្ញាតពីចៅក្រម។

ក្រោយពីបានបញ្ចប់កិច្ចពិភាក្សាដេញដោលនេះរួច ចៅក្រមស៊ើបសួរនឹងសម្រេចចេញដីកាសម្រេចអោយឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើចៅក្រមមានសុភវិនិច្ឆ័យថា ការចេញដីកានេះជាមធ្យោបាយចាំបាច់ដែលត្រូវធ្វើ។ បន្ទាប់ពីចេញដីកាសម្រេចអោយឃុំខ្លួនបណ្តោះអាសន្នរួច ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅដល់ព្រះរាជអាជ្ញា ព្រមទាំងត្រូវចោទផងដែរ ។

### ២.១.៣ នីតិវិធីចេញដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្ន

នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានផ្តល់អំណាចថាមានតែចៅក្រមស៊ើបសួរមានសិទ្ធិអំណាច់ផ្តាច់មុខ ក្នុងការសម្រេចចិត្តអំពីការឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ ។ ហើយការចេញដីកាសម្រេចនេះដែរ ត្រូវតែធ្វើការពិភាក្សាយ៉ាងជាក់ច្បាស់បំផុតដើម្បី កុំអោយប៉ះពាល់ទៅលើសិទ្ធិសេរីភាពរបស់ជនត្រូវចោទ។ មុននឹងសម្រេចចិត្តក្នុងការចេញដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្នចៅក្រមត្រូវធ្វើការតាក់តែងរូបមន្តឲត្រូវតាមទម្រង់នៃដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្នដើម្បីឲមានភាពស៊ីចង្វាក់គ្នាទៅតាមរូបមន្ត។ ទម្រង់នៃដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្នបានបញ្ជាក់យ៉ាងពិស្តារអំពីដើមដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្ន អង្គហេតុ និងអង្គច្បាប់ ព្រមទាំងសំអាងហេតុនៃសេចក្តីសម្រេច និងសម្រេចបញ្ចប់ ដែលយើងនឹងលើកយកមកសិក្សាដូចខាងក្រោមៈ

### ២.១.៣.១ ដើមដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

នៅក្នុងដើមដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងគម្រូ នៃរូបមន្តដែលតាក់តែងដោយ ក្រសួងយុត្តិធម៌តាមរយៈការភ្ជាប់មកជាមួយលិខិតលេខៈ ១២០ កយ.ប/ ២០១៦ ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៤ ត្រូវសរសេរនូវចំណុចមួយចំនួនដូចខាងក្រោម[59]៖

- ឈ្មោះនៃតុលាការ (សាលាដំបូងរាជធានី-ខេត្ត) *លេខ និងកាលបរិច្ឆេទសំណុំរឿងព្រហ្មទណ្ឌ និងសំណុំរឿងស៊ើបសួរ
- ឈ្មោះចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអម
- មាត្រាដែលពាក់ព័ន្ធ និងការឃុំខ្លួន
- លេខ និងកាលបរិច្ឆេទនៃដីកាបញ្ជា រឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ឈ្មោះបទល្មើស និងអត្ថបទច្បាប់ដែលត្រូវផ្ដន្ទាទោស
- យោងលើកំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង
- យោងលើកំណត់ហេតុននៃការពិភាក្សាដេញដោល និងការកត់សម្គាល់របស់ភាគីជាដើម។

### ២.១.៣.២ ស្ថានភាពអង្គហេតុ និងអង្គច្បាប់

- ចៅក្រមស៊ើបសួរត្រូវដាក់បញ្ចូលឈ្មោះបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ ។
- ចៅក្រមស៊ើបសួរត្រូវសង្ខេបពីអង្គហេតុនៃរឿងក្ដី ។
- ចៅក្រមស៊ើបសួរត្រូវសង្ខេបពីសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ ២ ឬ ៣ បន្ទាត់ដាក់បញ្ចូល ។ តើតំណាងអយ្យការមានសំអាងអ្វីខ្លះ ដែលស្នើសុំឱ្យឃុំ ឬ មិន ឃុំខ្លួន ធ្វើយ៉ាងនេះដើម្បីបង្ហាញថា ចៅក្រមស៊ើបសូរបានពិចារណាទៅលើមូលហេតុដែល តំណាងអយ្យការបានលើកឡើង។

[59] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្ដីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។

- ចៅក្រមស៊ើបសួរត្រូវធ្វើសេចក្តីសង្ខេបពីការកត់សម្គាល់ ឬការអះអាង របស់ជនត្រូវចោទ ឬមេធាវីរបស់ជនត្រូវចោទ ២ ឬ ៣ បន្ទាត់[60] ។

### ២.១.៣.៣ សំអាងហេតុនៃ និងសម្រេចបញ្ចប់

ចៅក្រមស៊ើបសួរត្រូវតែប្រាកដថាជនត្រូវចោទពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ[61] ។ អាស្រ័យហេតុនេះ ចៅក្រមស៊ើបសួរត្រូវពិនិត្យមើលថាប្រសិនបើរកឃើញពិរុទ្ធភាព ក្រោយពេលសវនាការទោសជាប់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ ឬអត់ ។

ចៅក្រមស៊ើបសួរត្រូវសរសេរនូវការយល់ឃើញរបស់ខ្លួន ឆ្លើយតបនឹងសំអាងនានា ដែលបានលើកឡើងដោយភាគីដូចជា តំណាងអយ្យការ ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ ។ ទន្ទឹមនេះនៅក្នុងចំណុចនេះដែរ ចៅក្រមស៊ើបសួរត្រូវបង្ហាញមូលហេតុនៃការឃុំខ្លួនចំនួនមួយ ឬ ច្រើន[62]ដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដោយពន្យល់បង្ហាញពីអង្គហេតុគាំទ្រទៅលើមូលហេតុនីមួយៗ ដែលចៅក្រមស៊ើបសួរបានលើក ។

## ២.១.៤ ការសម្រេចទាក់ទង នឹងអនីតិជនអាយុក្រោម១៤ឆ្នាំ

អនីតិជនដែលមានអាយុតិចជាង ១៤ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នបានទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឲឪពុកម្តាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអាណាព្យាបាលត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្នរងចាំសេចក្តីសម្រេចរបស់តុលាការ។ ពោលគឺចំពោះតែអនីតិជនដែលមានអាយុក្រោម ឬ តិចជាង១៤ឆ្នាំប៉ុណ្ណោះ ដែលមិនត្រូវបានចេញសេចក្តីសម្រេចឲឃុំខ្លួនបណ្តោះអាសន្ន ដោយត្រូវអោយឋិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់អាណាព្យាបាល ឬអ្នកថែទាំ[63]។

## ២.១.៥ អានុភាពនៃដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្ន

ការចេញដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមត្រូវវិនិច្ឆ័យយ៉ាងល្អិតល្អន់ ព្រោះវាស្មើទៅនឹងការសម្រេចដកហូតសិទ្ធិសេរីភាពរបស់ជនត្រូវចោទ។ ហេតុនេះការចេញដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្ន

[60] សេចក្តីណែនាំលេខ: ១២០កយ.រប/១៤ របស់ក្រសួងយុត្តិធម៌( ចំណុច1.ស្ថានភាពអង្គហេតុ និងអង្គច្បាប់ ) ចុះនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២០៤។

[62] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២០៥។

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២១២។

ចៅក្រមត្រូវកំណត់អំពីរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នឲបានច្បាស់លាស់នៅក្នុងដីកានោះ។ យ៉ាងណាមិញ ដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្ននេះ មានទំហំត្រឹមតែជាសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ប៉ុន្តែពុំទាន់មានអានុភាពបង្គាប់ឲប្រធានមណ្ឌលពន្ធនាគារ ឬមន្ទីរឃុំខ្លួនទទួលយក ឬ ឃុំខ្លួនលើជនត្រូវចោទដែលបានកំណត់ក្នុងដីកាសម្រេចឲឃុំខ្លួននោះទេ។ ដើម្បីអោយការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទមានអានុភាពបង្គាប់ ចៅក្រមស៊ើបសួរត្រូវចេញដីកាមួយទៀត ដែលយើងហៅថា ដីកាបង្គាប់ឲឃុំខ្លួន។

## ២.២ ដីកាបង្គាប់ឲឃុំខ្លួនបណ្តោះអាសន្ន

មានតែចៅក្រមស៊ើបសួរទេដែលអាចចេញដីកាបង្គាប់ឲឃុំខ្លួនបាន។ ការចេញដីកានេះទៀតសោត មិនមែនចៅក្រមស៊ើបសួរអាចចេញតាមអំពើចិត្តដោយពុំមានមូលដ្ឋានគតិយុត្តសំអាងហេតុ ឬ កម្មវត្ថុនៃដីកានោះទេ ពោលចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទនោះជា កម្មវត្ថុនៃដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្ន។

ដូចនេះដើម្បីសិក្សាស្វែងយល់អោយកាន់តែលម្អិតយ៉ាងជាក់ច្បាស់ យើងខ្ញុំនឹងធ្វើការលើកឡើងបង្ហាញនូវចំនុចសំខាន់ៗដែលទាក់ទងទៅនិងដីកាបង្គាប់ឲឃុំខ្លួន ថាតើនៅក្នុងដីកានេះមានភាពចាំបាច់យ៉ាងណាខ្លះ ក៏ដូចជាការអនុវត្តដីកានេះត្រូវធ្វើឡើងយ៉ាងដូចម្តេចខ្លះ។

### ២.២.១ និយមន័យដីកាបង្គាប់ឲឃុំខ្លួន

ដីកាបង្គាប់ឲឃុំខ្លួន គឺជាដីកាមួយដែលបិតនៅក្នុងវិធានការណ៍និរន្តរាយផងដែរ។ ដីកានេះចេញដោយចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។ ប៉ុន្តែចៅក្រមស៊ើបសួរ មិនអាចចេញដីកាបង្គាប់ឲឃុំខ្លួនមុនដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្ននោះទេ ព្រោះដោយហេតុថាដីកាបង្គាប់ឲឃុំខ្លួនបណ្តោះអាសន្នត្រូវបំពេញបន្ថែមទៅលើដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្ន។

ដីកាបង្គាប់ឲឃុំខ្លួនគឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲទទួល និងឲឃុំខ្លួនជនត្រូវចោទ[64]។ ពោលគឺលុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន មានន័យថាចាំបាច់ត្រូវតែចេញដីកាសម្រេចឲឃុំខ្លួនបណ្តោះអាសន្ន ទើបចៅក្រមមានមូលដ្ឋានគតិយុត្តសំអាងហេតុត្រឹមត្រូវដែលនាំឲចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲឃុំខ្លួនបណ្តោះអាសន្ន។

[64] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២២០។

### ២.២.២ ការចុះនិទ្ទេសលើដីកាបង្គាប់ឲឃុំខ្លួន

ការចុះនិទ្ទេសក្នុងដីកាបង្គាប់ឲឃុំខ្លួនគឺជាការធ្វើឡើងដើម្បីកំណត់សម្គាល់នៅអត្តសញ្ញាណផ្សេងៗ ទាក់ទងទៅនឹងជនត្រូវចោទ ឬអត្តសញ្ញាណតួនាទីរបស់ចៅក្រមផងដែរ។

ដីកាបង្គាប់ឲឃុំខ្លួនត្រូវមានការចុះនិទ្ទេសពិស្តារដូចតទៅះ

- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើស នេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមចេញដីកា[65]។

ដីកាបង្គាប់ឲឃុំខ្លួន ត្រូវមានចុះកាលបរិច្ឆេទដែលចេញដីកា និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ ព្រមទាំងមានបោះត្រាផងដែរ។

### ២.២.៣ ការអនុវត្តដីកាបង្គាប់ឲឃុំខ្លួន

ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានចែងថា ការអនុវត្តដីកាបង្គាប់ឲ្យឃុំខ្លួនប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឲ្យឃុំខ្លួនរហូតទាល់តែបានទទួលការឲ្យដំណឹងអំពីការដោះលែងឲ្យមានសេរីភាពវិញ ។ ត្រង់ចំណុចនេះចង់បង្ហាញថា ប្រសិនបើគ្មានការបង្គាប់ឲឃុំខ្លួននោះទេប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនគ្មានសិទ្ធិ ក្នុងការយកជនត្រូវចោទទៅឃុំនោះទេ ។ ចំពោះការដោះលែងវិញ ប្រសិនបើគ្មានសេចក្តីសម្រេចរបស់តុលាការទេ ក៏ពុំមាននរណាមានសិទ្ធិដោះលែងជនត្រូវចោទឲមានសេរីភាពដែរ។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវរក្សាទុកដើមដីកាបង្គាប់ឲ្យឃុំខ្លួន ឬ ចុងដីកានេះ ដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម[66] ។ បុគ្គលណាដែលជាប់ឃុំ ដោយគ្មានសេចក្តីសម្រេចពីតុលាការណាមួយ ដោយគ្មានដីកាបង្គាប់ឲឃុំខ្លួននោះទេ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនមិនអាចឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានដីកាបង្គាប់ឲឃុំខ្លួនបានឡើយ[67] ព្រោះប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនអាចប្រឈមមុខទៅនឹងកាតប្រព្រឹត្តបទ

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២២១។
[66] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២២២។
[67] ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១, មាត្រា១៧ និងមាត្រា១៩ ។

ល្មើសទាក់ទិននឹងការបង្ខាំងមនុស្សដោយខុសច្បាប់ [68] ។ ដោយច្បាប់ធានារ៉ាប់រងមិនឲរំលោភបំពានទៅលើរូបកាយបុគ្គលណាម្នាក់ឡើយ ហើយច្បាប់ធានាការពារជីវិត កិត្តយស កេរ៏តឈ្មោះ សេចក្តីថ្លៃថ្នូររបស់បុគ្គលគ្រប់រូប ប៉ុន្តែបើមានការចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនជនណាម្នាក់ នឹងអាចធ្វើទៅកើតលុះត្រាតែមានបញ្ញត្តិច្បាប់ចែងជាធរមាន ដែលច្បាប់ហាមឃាត់មិនឲធ្វើឡើងចំពោះការបង្ខិតបង្ខំលើរូបកាយ ឬ ប្រព្រឹត្តកម្មណាមួយដែលបន្ថែមទណ្ឌកម្មអនុវត្តទៅលើជនជាប់ឃុំ ឬ ជាប់ពន្ធនាគារ[69]។

## ២.៣ សិទ្ធរបស់ជនត្រូវចោទក្នុងការឃុំខ្លួនបណ្តោះអាសន្ន

ស្ថិតនៅក្នុងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទត្រូវបានឃុំក្នុងពន្ធនាគារប៉ុន្តែទោះជាយ៉ាងណាក៏ដោយការឃុំខ្លួននោះ គ្រាន់តែជាការរក្សាជនត្រូវចោទនៅក្នុងពន្ធនាគារប៉ុណ្ណោះ ដើម្បីរង់ចាំការកាត់ក្តីស្វែងរកទោសថាតើជនត្រូវចោទនោះមានទោស ឬក៏គ្មានទោស។ ម៉្យាងវិញទៀត ជនត្រូវចោទត្រូវចាត់ទុកថាឥតទោសដរាបណាមិនទាន់មានការប្រកាសទោសស្ថាពរដោយតុលាការ [70] ។ ដោយសារមូលហេតុបែបនេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាយើង ក៏ដូចជាលិខិតបទដ្ឋានគិតិយុត្តដែលចុះជាធរមាននានា បានចែងនិងទទួលមួយចំនួនរបស់ជនត្រូវចោទ។ ការយល់ព្រមឲមានសិទ្ធរបស់ជនត្រូវចោទក្នុងដំណាក់កាលឃុំខ្លួនបណ្តោះអាសន្ននេះ ព្រោះថាដើម្បីឲជនត្រូវចោទទទួលបានសិទ្ធិការពារខ្លួនក៏ដូចជាសិទ្ធិផ្សេងៗទៀត។ បែបនេះហើយ ទើបយើងនឹងយកសិទ្ធជនត្រូវចោទក្នុងការឃុំខ្លួនបណ្តោះអាសន្ននេះមកសិក្សាស្វែងយល់បន្ថែមដូចខាងក្រោមៈ

### ២.៣.១ សិទ្ធក្នុងការស្នើសុំបំពេញកិច្ច

ជនត្រូវចោទដែលកំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នមានសិទ្ធិ ស្នើសុំឱ្យចៅក្រម ស៊ើបសួរបំពេញកិច្ចផ្សេងៗ ដែលខ្លួនយល់ឃើញថាចាំបាច់ ដើម្បីបញ្ជាក់ដើម្បីនត្តិភាពនៃទោស របស់ខ្លួនបាន ។

នៅគ្រប់ពេលនៃការស៊ើបសួរ ជនត្រូវចោទអាចស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ច មួយចំនួនដូចជាៈ

- ការសួរចម្លើយខ្លួន (ជនត្រូវចោទខ្លួនឯង)

---

[68] ក្រមព្រហ្មទណ្ឌ, លេខ នស/រកត/០៩០៨/១០៥៥, ២៥ កញ្ញា ២០០៨, មាត្រា២៥៣។

[69] ច្បាប់ស្តីពីពន្ធនាគារ, ឆ្នាំ២០១១, មាត្រា២៥ និងមាត្រា៥៣។

[70] រដ្ឋធម្មនុញ្ញ, ២៤ កញ្ញា ១៩៩៣, មាត្រា៣៨, កថាខណ្ឌទី៦។

- ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ការស្តាប់ចម្លើយសាក្សី
- ការសួរតទល់
- ការចុះទៅកន្លែងកើតហេតុ[71] ។

ចំពោះទម្រង់នៃការស្នើសុំនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ជាក់ពីភាព ប្រាកដ ច្បាស់លាស់ និងត្រូវសរសេរបញ្ជាក់ពីសំអាងហេតុឱ្យបានត្រឹមត្រូវ ។ ប្រសិនបើ ចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងថេរវេលា ១ (មួយ) ខែ បន្ទាប់ពីបានទទួលពាក្យសុំ ។ ដីនេះត្រូវតែមានសំអាង និងត្រូវជូនដំណឹងជនត្រូវចោទ និងព្រះរាជអាជ្ញា ។

### ២.៣.២ សិទ្ធស្នើសុំធ្វើកោសលវិច័យ

ជនត្រូវចោទមានសិទ្ធិស្នើសុំចៅក្រមស៊ើបសួរឲ្យធ្វើកោសលវិច័យបាន។ ក្នុងករណីមានបញ្ហាបច្ចេកទេសកើតឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យ សុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ។

ប្រសិនបើយល់ឃើញថាការស្នើសុំនោះជាការចាំបាច់ដើម្បីបញ្ជាក់ឲ្យឃើញពីការពិត ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក [72] ។ ចៅក្រមស៊ើបសួរនឹងសម្រេចដោយចេញដីកាចាត់តាំងអ្នកជំនាញដែលមានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិ ឬចាត់តាំងអ្នកជំនាញដែលមិនមាន ឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិឲ្យធ្វើកោសលវិច័យ[73]។ ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យស្នើសុំនោះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ១(មួយ)ខែ នៅក្នុងករណីនេះគឺករណីការស្នើសុំធ្វើឡើងដោយជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែបើការស្នើសុំធ្វើឡើងដោយព្រះរាជអាជ្ញាកោសលវិច័យត្រូវដាក់បញ្ចូលនៅក្នុងសំណុំរឿង។ ចៅក្រមស៊ើបសួរត្រូវកោះហៅជនត្រូវចោទ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដើម្បី ប្រាប់ឲ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ ។

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា១៣៣។
[72] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២១៧។
[73] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា១៧០, កថាខណ្ឌទី៥។

ចៅក្រមស៊ើបសួរត្រូវកំណត់រយៈពេលមិនឲ្យតិចជាង ១០ (ដប់)ថ្ងៃ ដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យសុំកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ”។ ចំពោះទម្រង់នៃពាក្យស្នើសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យត្រូវធ្វើឡើងដោយមានសំអាងហេតុ និងជាលាយលក្ខណ៍អក្សរ។ កាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យស្នើសុំកោសលវិច័យ ឬប្រតិកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចដោយដីកាដោយមានសំអាង ហេតុ។ ប្រសិនបើការស្នើសុំធ្វើឡើងដោយជនត្រូវចោទដីកាត្រូវសម្រេចក្នុងរយៈពេល ១ (មួយ)ខែ និងត្រូវជូនដំណឹងដល់ជនត្រូវចោទផងដែរ។ គ្រប់ពាក្យសុំធ្វើកោលសវិច័យបន្ថែម ឬប្រតិកោសល វិច័យធ្វើឡើងក្រោយផុតរយៈពេលកំណត់ដោយចៅក្រមស៊ើបសួរត្រូវដាក់ចូលក្នុងសំណុំរឿង ។ ក្នុងករណី ចៅក្រមស៊ើបសួរមិនព្រមសម្រេចក្នុងរយៈពេលខាងលើនេះទេ ជនត្រូវចោទអាចធ្វើការប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរបាន ។

### ២.៣.៣ សិទ្ធិស្នើសុំនៅក្រៅឃុំ

ជនត្រូវចោទអាចដាក់ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំគ្រប់ពេលវេលា[74] ។ បន្ទាប់ពីទទួលបានពាក្យស្នើសុំនៅក្រៅឃុំនេះហើយ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនោះភ្លាមទៅព្រះរាជអាជ្ញាដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ក្រោយពីបានទទួលរួចហើយព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុតប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់រយៈពេលនេះទេគ្រាន់ តែកំណត់រយៈពេលនៃការសម្រេចដោយចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរសម្រេច យ៉ាងយូរបំផុតក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបញ្ជូនរឿងទៅព្រះរាជអាជ្ញា ។

ប្រសិនបើចៅក្រមស៊ើបសួរបដិសេដពាក្យសុំនៅក្រៅឃុំរបស់ខ្លួនជនត្រូវចោទអាចដាក់ពាក្យ សុំនៅក្រៅឃុំជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរដដែល ឬទៅសភាស៊ើបសួរក្នុងរយៈពេល ១(មួយ)ខែ បន្ទាប់ពីសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ក្រោយពីបានទទួលពាក្យសុំជាថ្មីម្តងទៀត ចៅក្រម ស៊ើបសួរត្រូវសម្រេចលើពាក្យសុំនេះក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃបន្ទាប់ពីទទួល។រីឯសភាស៊ើបសួរ ក្រោយពីបានទទួលពាក្យស្នើសុំនៅក្រៅឃុំរបស់ជនត្រូវចោទហើយត្រូវសម្រេចនៅក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃដូចចៅក្រមស៊ើបសួរ ដែរ។

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២១៧។

ប៉ុន្តែបើសិនជា ចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃទេ ជនត្រូវចោទ អាចដាក់ពាក្យប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

### ២.៣.៤ សិទ្ធជ្រើសរើសជ្រើសរើស ឬស្នើសុំ ឬចាត់តាំង ឬផ្លាស់ប្តូរមេធាវី

ជនត្រូវចោទដែលស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន មានសិទ្ធិជ្រើសរើសមេធាវីបានក្នុងករណីមិនទាន់បានជ្រើសរើស ឬអាចស្នើសុំមេធាវីក្នុងករណីខ្លួនពុំមានលទ្ធភាពឬមេធាវីត្រូវបាន ចាត់តាំងដោយតុលាការ ហើយគាត់ក៏អាចធ្វើការផ្លាស់ប្តូរមេធាវីបានដែរ ។

**សិទ្ធិជ្រើសរើសមេធាវី** នៅក្នុងករណីមុនពេលដែលការឃុំខ្លួនបណ្តោះអាសន្នត្រូវបានធ្វើឡើងប្រសិនបើជនត្រូវចោទពុំទាន់បានជ្រើសរើសមេធាវីនៅឡើយខ្លួនអាចជ្រើសរើសមេធាវីដែលជា សមាជិកគណៈមេធាវីដើម្បីការពារសិទ្ធិឲ្យខ្លួនបាន។

**សិទ្ធិស្នើសុំមេធាវី** ការស្នើសុំមេធាវីអាចធ្វើទៅបានប្រសិនបើជនត្រូវចោទជាជនក្រីក្រដែល គ្មានលទ្ធភាព។ ការស្នើសុំនេះ គឺត្រូវធ្វើឡើងដោយការស្នើសុំទៅកាន់គណៈមេធាវីដែលទទួលបន្ទុកការពារជនក្រីក្រ ឬមួយតាមបណ្តាអង្គការក្រៅរដ្ឋាភិបាលផ្សេងៗដែលមានផ្តល់ជំនួយផ្នែកច្បាប់ ជាពិសេសសេវាមេធាវីដោយឥតគិតថ្លៃ។

**សិទ្ធិទទួលបានការចាត់តាំងមេធាវីដោយតុលាការ** ជាការចាំបាច់ក្នុងករណីពិសេសមួយចំនួន។ បន្ទាប់ពីទទួលដំណឹងអំពីសិទ្ធិជ្រើសរើសមេធាវី និងសិទ្ធិស្នើសុំមេធាវី មេធាវីក៏អាចត្រូវបានចាត់តាំង ដោយតុលាការផងដែរ ។ នៅក្នុងដំណាក់កាលនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរករណីជន ត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេមេធាវី ត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលមានចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី[75]។ ករណីនៅក្នុងដំណាក់កាលជំនុំជម្រះជំនួយមេធាវីត្រូវតែមានជាដាច់ខាតនៅក្នុងករណីជនជាប់ចោទជាអនីតិជន ឬករណីបទល្មើសជាបទល្មើសឧក្រិដ្ឋ ។ បើទោះបីជាជនជាប់ចោទគ្មានលទ្ធភាពក្នុងការជ្រើសរើសមេធាវីក៏ដោយ ក៏មេធាវីត្រូវបានចាត់តាំងតាមគំនិតផ្តើមរបស់ប្រធានតុលាការនៅក្នុងលក្ខខណ្ឌដែល មានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី [76]។

---

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា១៤៣, កថាខណ្ឌទី៥។

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា៣០១។

### ២.៣.៥ សិទ្ធិប្តឹងជិតចិត្ត

**ការប្តឹងជិតចិត្ត** គឺជាសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងបដិសេធវត្តមានរបស់ចៅក្រមអាសនៈដោយពុំអនុញ្ញាតកុំឲ្យគាត់ទទួលបន្ទុករឿងក្តីណាមួយ។ ចៅក្រមនៅទីនេះ គឺសំដៅទៅលើ ចៅក្រម អាសនៈ ដែលមិនសំដៅទៅដល់ចៅក្រមខាងផ្នែកអយ្យការឡើយ។ ចៅក្រមអាសនៈនៅក្នុងនីតិវិធីព្រហ្មទណ្ឌអាចជា ចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះ ។

បណ្តឹងជិតចិត្ត អាចត្រូវទទួលបានពាក់ព័ន្ធតែចៅក្រមអាសនៈតែប៉ុណ្ណោះ[77] ។ ចំពោះមូលហេតុនៃការប្តឹងជិតចិត្ត មានដូចខាងក្រោមដែលត្រូវបានច្បាប់កំណត់យ៉ាងជាក់លាក់នៅក្នុងមាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖

- កាលណាចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតរបស់សហព័ទ្ធរបស់ចៅក្រមជាភាគីណា មួយនៅក្នុងរឿងក្តី
- កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី៦ ឬញាតិពន្ធដល់ថ្នាក់ទី៣ឬអតីត ញាតិពន្ធដល់ថ្នាក់ទី៣ របស់ភាគីណាមួយ
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ
- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគី ណាមួយ
- កាលណាចៅក្រមបានធ្វើជាសាក្សី ឬអ្នកជំនាញក្នុងរឿងក្តី
- កាលណាចៅក្រមជា ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឲ្យភាគីចំពោះរឿងក្តី ឬ
- កាលណាចៅក្រមបានចូលរួមក្នុងនាមជាមជ្ឈត្តករក្នុងរឿងក្តី ឬបានចូលរួមក្នុងការសម្រេច

សេចក្តីនៅសាលាដំបូងដែលបានប្តឹងឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែល បានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្តី ។

អំពីមូលហេតុនៃការប្តឹងជិតចិត្ត គឺក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់សម្រាប់គូភាគី ( ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ) អាចប្តឹងជិតចិត្តបាន។ ក្រៅពីការប្តឹងជិតចិត្តច្បាប់ក៏ទុកសិទ្ធិ ដល់ចៅក្រមក្នុងការដកខ្លួនពីរឿងក្តីផងដែរ។ ចៅក្រមដែលមានមូលហេតុត្រឹមត្រូវមិនព្រមចូលរួមក្នុងការស៊ើបសួរ ឬជំនុំជម្រះ

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា៥៥៦, កថាខណ្ឌទី១។

រឿងក្តីណាមួយនោះអាចសុំឲ្យគេជំនួសខ្លួនបាន[78] ។ ចៅក្រមដែលមាន បំណងចង់ដកខ្លួននោះត្រូវធ្វើពាក្យសុំ ពាក្យសុំនោះត្រូវដាក់ជូនប្រធានតុលាការរបស់ខ្លួនដើម្បីសម្រេច អនុញ្ញាត ឬមិនអនុញ្ញាតឲ្យដកខ្លួន។ សូមបញ្ជាក់ផងដែរថា សេចក្តីសម្រេចរបស់ប្រធានតុលាការមិនអាចតវ៉ាបានឡើយ ។

ការកំណត់បែបនេះ គឺក្នុងគោលបំណងជាការការពារសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួល បានការជំនុំជម្រះក្តីរបស់ខ្លួនប្រកបទៅដោយភាពយុត្តិធម៌។ ចៅក្រមអាចធ្វើការស្វែងរកយុត្តិធម៌បាន លុះត្រាណាតែគាត់អាចជៀសវាងនូវ អគតិទាំង៤ និងធានារក្សាឲ្យបាននូវ គតិទាំង៥[79] ។

ជនត្រូវចោទដែលចង់ប្តឹងជិតចិត្តចៅក្រមអាសនៈណាមួយ ត្រូវជូនពាក្យប្តឹងតាំងពីពេលដែល ខ្លួនបានដឹងពីមូលហេតុនៃការប្តឹងជិតចិត្ត បើពុំដូច្នេះទេមិនអាចទទួលបានឡើយ។ ប៉ុន្តែនៅក្រោយ ពេលបិទការពិភាក្សាដេញដោលពាក្យប្តឹងជិតចិត្តចៅក្រមមិនអាចធ្វើបានឡើយ ។

### ២.៣.៦ សិទ្ធិទទួលបានដំណឹងពីការមិនបញ្ចប់សំណុំរឿង

កាលណាចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរបានបញ្ចប់ចៅក្រមស៊ើបសួរត្រូវជូន ដំណឹងដល់ជនត្រូវចោទ និងមេធាវីប្រសិនបើមាន[80] ។ នៅពេលដែលមានការជូនពត៌មានអំពីការ បិទការស៊ើបសួរនេះក្រមនីតិវិធីព្រហ្មទណ្ឌបានទុកសិទ្ធិឲ្យព្រះរាជអាជ្ញាក្នុងការស្នើសុំឲ្យចៅក្រម ស៊ើបសួរក្នុងការបំពេញកិច្ចណាមួយ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវឲ្យចៅក្រមធ្វើការស៊ើបសួរថ្មីនោះ ព្រះរាជអាជ្ញាត្រូវធ្វើតាម ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា[81]។

ប៉ុន្តែចំពោះជនត្រូវចោទវិញ តើគាត់អាចមានសិទ្ធិស្នើសុំឲ្យបំពេញកិច្ចដូចព្រះរាជអាជ្ញាដែល មានចែងនៅក្នុងមាត្រា ១៣៣ (ការស្នើសុំឲ្យបំពេញកិច្ចដោយជនត្រូវចោទ) បានដែរ ឬទេ ?

អំពីបញ្ហានេះមានការបកស្រាយផ្សេងៗគ្នាពីសំណាក់សិស្សនិស្សិត សាស្ត្រាចារ្យ ឬពី សំណាក់អ្នកអនុវត្តច្បាប់។ មានមតិពីរនៃការយល់ឃើញអំពីបញ្ហានេះដោយៈ

---

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា៥៥។

[79] ហៃល ចំរើន, មរតកយុត្តិធម៌ខ្មែរ(បោះពុម្ពផ្សាយដោយរោងពុម្ពភ្នំពេញ,ឆ្នាំ២០១០), ទំព័រទី២៩៧ ដល់ទំព័រទី៣០០។

[80] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២៤៦, កថាខណ្ឌទី១។

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា១៣២។

**មតិទីមួយៈ** យល់ឃើញថាជនត្រូវចោទមានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ច ដូចដែលមានចែងនៅក្នុង មាត្រា ១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបាន។

**មតិទីពីរៈ** បកស្រាយថានៅពេលដែលចៅក្រមស៊ើបសួរជូនដំណឹងដល់ជនត្រូវចោទអំពីការ បិទការស៊ើបសួរ ហើយ ជនត្រូវចោទពុំអាចស្នើសុំឲ្យបំពេញកិច្ចបានឡើយ មានន័យថាបើគាត់ចង់ស្នើសុំឲ្យបំពេញកិច្ចដូចមាន ចែងនៅក្នុងមាត្រានេះគាត់ត្រូវស្នើសុំ ឲ្យបានមុនការជូនដំណឹងអំពីការបិទការស៊ើបសួរ។

អំពីបញ្ហានេះប្រាកដជាមានចម្ងល់ ហើយថាបើសិនជាមិនអនុញ្ញាតឲ្យជនត្រូវចោទស្នើសុំឲ្យបំពេញកិច្ច ចាំ បាច់ជូនដំណឹងដល់គាត់ធ្វើអ្វី ?

**មតិទីពីរបានបកស្រាយបន្ថែមថាៈ** វាគ្រាន់តែជាការជូនដំណឹងឲ្យដល់ជនត្រូវចោទឲ្យបាន ដឹងតាមការកំណត់ របស់ច្បាប់តែប៉ុណ្ណោះ ។

### ២.៣.៧ . សិទ្ធិទទួលបានដំណឹងពីដីកាដំណោះស្រាយ

បន្ទាប់ពីការជូនពត៌មានអំពីការបិទការស៊ើបសួរ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូច ចៅក្រមស៊ើប សួរដែរថាការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរជា លាយលក្ខណ៍អក្សរ និងមាន សំអាងហេតុ។ នៅក្នុងសេចក្ដីសន្និដ្ឋានស្ថាពរនេះ ព្រះរាជអាជ្ញាអាច ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូន ខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែង ការចោទប្រកាន់[82] ។

ក្រោយពីធ្វើដីកាសន្និដ្ឋានស្ថាពររួច ព្រះរាជអាជ្ញាត្រូវបញ្ជូនដីកានោះដោយភ្ជាប់ជាមួយសំណុំរឿងទៅ កាន់ចៅក្រមស៊ើបសួរ។ បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានស្ថាពររួច ចៅក្រមស៊ើបសួរ ត្រូវធ្វើដីកាដំណោះស្រាយ ដីកានេះអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ឬដីកាបញ្ជូនឲ្យសម្រេចរឹបអូស[83] ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការធ្វើដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរព តាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជ អាជ្ញានោះទេ[84]។

---

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២៤៦, កថាខណ្ឌទី៥។

[83] ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២នៃក្រមព្រហ្មទណ្ឌ, ០៩ មិថុនា២០១៣, មាត្រា២៤៧ កថាខណ្ឌទី១។

[84] ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២នៃក្រមព្រហ្មទណ្ឌ, ០៩ មិថុនា២០១៣, មាត្រា២៤៧ កថាខណ្ឌទី៤។

ក្រោយពីការធ្វើដីកាដំណោះស្រាយរួច ដីកានោះត្រូវជូនដំណឹងដល់ជនត្រូវចោទក្នុងរយៈពេលដ៏ខ្លីបំផុត។ ចំពោះរយៈពេលដ៏ខ្លីនេះច្បាប់មិនបានកំណត់ជាក់លាក់នោះទេ ប៉ុន្តែចៅក្រមត្រូវគិតគូរពីរយៈពេលណាមួយដែលសមរម្យ ។

មានសំណួរចោទឡើងថា **ក្រោយពីបានទទួលដំណឹងពីដីកាដំណោះស្រាយរួច តើជនត្រូវ ចោទអាចប្ដឹងឧទ្ធរណ៍ចំពោះដីកានេះបានដែរ ឬទេ** ?

បើពិនិត្យនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ជំពូកទី២ ដែលស្ដីអំពីបណ្ដឹងឧទ្ធរណ៍ចំពោះដីកា របស់ចៅក្រមស៊ើបសួរដោយជនត្រូវចោទ ពុំមានចំណុចណាមួយអនុញ្ញាតឲ្យជនត្រូវចោទអាចប្ដឹង ឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយឡើយ ទោះជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែង ការចោទប្រកាន់ ឬដីកាបញ្ជូនឲ្យសម្រេចរឹបអូសក៏ដោយ[85] ។ ប៉ុន្តែចំពោះដើមបណ្ដឹងរដ្ឋប្បវេណីវិញ ការប្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយដូចមានចែងនៅក្នុងដីកាដំណោះស្រាយគឺអាចធ្វើបាន[86] ។

### ២.៣.៨ សិទ្ធិស្នើសុំឲ្យបិទសំណុំរឿង

នៅពេលផុតចិរវេលា ១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចោទប្រកាន់ជនត្រូវចោទអាចសុំឲ្យចៅក្រម ស៊ើបសួរបិទការស៊ើបសួរ។ នៅក្នុងរយៈពេល ១(មួយ)ខែ គិតចាប់ពីថ្ងៃទទួលពាក្យសុំនេះ ចៅក្រម ស៊ើបសួរត្រូវតែសម្រេច[87]។ បើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេលនេះទេ ជនត្រូវចោទអាច ប្ដឹងទៅសភាស៊ើបសួរដែលធ្វើអធិបញ្ជាឲ្យចៅក្រមស៊ើបសួរសម្រេច។ នោះជាសិទ្ធិមួយដែលផ្ដល់ ដោយក្រមនីតិវិធីព្រហ្មទណ្ឌដល់ជនត្រូវចោទ ដើម្បីជៀសវាងការខ្ជីខ្ជារបស់ចៅក្រមស៊ើបសួរដែល អាចកើតមានឡើង ។

អំណាចដែលទទួលស្គាល់អំពីការប្ដឹងសុំបិទសំណុំរឿងដល់ជនត្រូវចោទនេះ អាចត្រូវបាន ប្រើប្រាស់ដោយមេធាវីរបស់ជនត្រូវចោទបាន[88] ។

---

[85] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២៦៧។

[86] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២៦៨, វាក្យខណ្ឌទី៥។

[87] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២៨៦។

[88] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២៨៩, កថាខណ្ឌទី៣។

## ២.៤ ការសម្រេចឲដោះលែងនៅក្រៅឃុំ

ចៅក្រមស៊ើបសួរអាចបង្គាប់ឲដោះលែងជនត្រូវចោទឲនៅក្រៅឃុំវិញបានគ្រប់ពេលវេលា។ ចំពោះការដោះលែងក៏អាចធ្វើឡើង តាមបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា ឬ បណ្ដឹងសុំរបស់ជនត្រូវចោទផងដែរ។ ជាមួយគ្នានេះផងដែរ កាលណាចៅក្រមស៊ើបសួរសម្រេចឲដោះលែងជនត្រូវចោទដែលជាប់ឃុំបណ្ដោះអាសន្ន ជនត្រូវចោទនោះត្រូវរក្សាទុកនៅក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲដោះលែងជនត្រូវចោទនោះភ្លាម។ ក្នុងករណីដែលមានបណ្ដឹងឧទ្ធរណ៍ របស់ព្រះរាជអាជ្ញាអំពីដីកាឲដោះលែងឲនៅក្រៅឃុំ ឬ លើកលែងចោទប្រកាន់នោះ ជនត្រូវចោទដែលជាប់ឃុំត្រូវរក្សាទុកនៅក្នុងពន្ធនាគារ រហូតទាល់តែសភាស៊ើបសួរសម្រេចអំពីបណ្ដឹងឧទ្ធរណ៍[89]។

### ២.៤.១ ការដោះលែងជនត្រូវចោទនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ

កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងឲ្យនៅក្រៅឃុំ នោះចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ ដោយបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាពិនិត្យ ហើយ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត (មិនត្រូវលើសពី៥ ថ្ងៃ គិតពីថ្ងៃ ទទួលសំណុំរឿងមកពិនិត្យ) ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពី ការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ប៉ុន្តែមានករណីពិសេស ដែលមានភាពបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញានោះឡើយ តែចៅក្រមស៊ើបសួរត្រូវចង្អុលបង្ហាញប្រាប់ពី មូលហេតុនៃភាពបន្ទាន់នោះនៅក្នុងដីកាសម្រេចរបស់ខ្លួន[90] ។

### ២.៤.២ ការដោះលែងជនត្រូវចោទនៅក្រៅឃុំដោយបណ្ដឹងព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឲ្យដោះលែងជនត្រូវចោទបាន ហើយចៅក្រមស៊ើបសួរត្រូវតែសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ។ បើសិនជារយៈពេល ៥ ថ្ងៃនេះកន្លងផុតទៅចៅក្រមស៊ើបសួរ មិនបានសម្រេចព្រះរាជអាជ្ញាអាចប្ដឹងសុំ

[89] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២៧៦។

[90] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២១៥។

តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចស៊ើបសួរត្រូវតែសម្រេចក្នុងរយៈពេល៥ ថ្ងៃជំនួសចៅក្រមស៊ើបសួរវិញ[91] ។

### ២.៤.៣ ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំដោយជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរ ត្រូវបញ្ជូនពាក្យសុំរបស់ជនត្រូវចោទ និងសំណុំរឿងទៅព្រះរាជអាជ្ញាភ្លាម ដើម្បីពិនិត្យ និងផ្តល់យោបល់ ហើយព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត (មិនត្រូវលើសពី ៥ថ្ងៃ គិតពី ថ្ងៃទទួលសំណុំរឿងមកពិនិត្យនោះឡើយ) ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ថ្ងៃ បន្ទាប់ពីបានបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

បើសិនជារយៈពេល ៥ ថ្ងៃនេះកន្លងផុតទៅចៅក្រមស៊ើបសួរមិនបានសម្រេច ជនត្រូវចោទអាច ធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ ។

ក្នុងករណីដែលមានការបដិសេធនឹងពាក្យសុំឲ្យនៅក្រៅឃុំ ជនត្រូវចោទអាចដាក់ពាក្យសុំសាជាថ្មី ម្តងទៀតទៅចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរក្នុងរយៈពេល ១ ខែ បន្ទាប់ពីមានសេចក្តីសម្រេច បដិសេធពាក្យសុំលើកមុន ។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវតែសម្រេចលើពាក្យនេះក្នុងរយៈ ពេល ៥ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។

នៅក្នុងករណីដែលចៅក្រមស៊ើបសួរ សម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ ដីកាសម្រេច នេះ ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងប្រធានពន្ធនាគារ ។ បទប្បញ្ញត្តិនៃមាត្រា២៧៦ ស្តីពីការ ដោះលែង ជនត្រូវចោទដែលជាប់ឃុំឲ្យមានសេរីភាព នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្ត ។

ការដោះលែងជនត្រូវចោទដែលជាប់ឃុំឲ្យមានសេរីភាព នៃក្រមនីតិវិធី ព្រហ្មទណ្ឌបានចែងថា "កាលណាចៅក្រមស៊ើបសួរសម្រេចឲ្យដោះលែងជនត្រូវចោទ ដែលកំពុងជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះ ត្រូវបានរក្សាទុកក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាលើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យធ្វើការដោះលែងជនត្រូវចោទភ្លាម[92] ។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញាត្រូវដាក់បញ្ចូលក្នុងនីតិវិធី ។

[91] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២១៦

[92] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២៧៦។

ត្រូវធ្វើដូចគ្នានេះដែរ ចំពោះដីកាលើកលែងចោទប្រកាន់ កាលណាដីកានេះមានអាន ដោះលែងជនត្រូវចោទដែលជាប់ឃុំ ។ ក្នុងករណីដែលមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីកាលែងឲ្យនៅក្រៅឃុំ ឬលើកលែងចោទប្រកាន់នោះ ជនត្រូវចោទដែលជាប់ឃុំត្រូវរក្សាទុកក្នុងពន្ធនាគ រហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្ដឹងឧទ្ធរណ៍ ”។

កាលណាចៅក្រមស៊ើបសួរសម្រេចឲ្យដោះលែងជនត្រូវចោទនៅក្រៅឃុំ ចៅក្រមនេះអាចដាក់ជននោះឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការវិញតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២២៣ ដល់មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[93] ។

## ២.៤.៤ ការដោះលែងជនត្រូវចោទជាអនីតិជននៅក្រៅឃុំ[94]

ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ដោយគំនិតផ្ដួចផ្ដើមរបស់ខ្លួន ។ ចៅក្រមស៊ើបសួរដែលមានបំណងដោះលែងអនីតិជនឲ្យនៅក្រៅឃុំ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលខ្លីបំផុត ។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាម ដោយមិនរង់ចាំយោបល់ របស់ព្រះរាជអាជ្ញា ឬទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។ ចៅក្រមស៊ើបសួរត្រូវ ចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះ នៅក្នុងដីកាសម្រេចរបស់ខ្លួន ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់។ ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំនោះមន្ទីរ ឬការិយាល័យត្រូវ ចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណ៍អនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការ សម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាល លើអនីតិជននោះ[95] ។

---

[93] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២១៧។

[94] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦, មាត្រា៤១។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ព្រះរាជអាជ្ញា អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងអនីតិជនអាចសុំ ឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ។ មេធាវីអាចសុំដោះលែងអនីតិជនឲ្យនៅ ក្រៅឃុំបានដោយមានការយល់ព្រមពីអនីតិជន ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ ។

### ២.៤.៥ ការជូនដំណឹងអំពីការដោះលែងឲនៅក្រៅឃុំ

បន្ទាប់ពីវិនិច្ឆ័យដោះលែងជនត្រូវចោទរួចរាល់ចៅក្រមត្រូវចេញ **ដីកាសម្រេចឲដោះលែងនៅក្រៅឃុំ។** ដីកាសម្រេចដោះឲនៅក្រៅឃុំត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ បន្ថែមពីនេះក្រមនីតិវិធីក៏បានអនុវត្តចំពោះ ការដោះលែងជនត្រូវចោទដែលជាប់ឃុំឲមានសេរីភាព[96] ផងដែរ ។

ក្នុងករណីដែលចៅក្រមយល់ឃើញថា បទល្មើសដែលជនត្រូវចោទប្រព្រឹត្តពុំអាចដោះលែងឲនៅក្រៅឃុំបាននោះចៅក្រមត្រូវចេញ **ដីកាមិនព្រមដោះលែងឲនៅក្រៅឃុំ។** ដោយដីកាមិនព្រមដោះលែងឲនៅក្រៅឃុំត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[97]។

ទោះបីជាចៅក្រមសម្រេចដោះលែងអោយនៅក្រៅឃុំក៏ ចៅក្រមក៏អាចដាក់ឲជននោះស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការផងដែរ ដោយត្រូវគោរពកាតព្វកិច្ចនានាក្រោមការត្រួតពិនិត្យរបស់តុលាការ។ ការធ្វើការត្រួតពិនិត្យបែបនេះដើម្បីជៀសវាងការប្រព្រឹត្តនូវបទល្មើស ក៏ដូចជាទង្វើប៉ះពាល់សណ្តាប់ធ្នាប់សង្គមនានា។

## ២.៥ ការត្រួតពិនិត្យតាមផ្លូវតុលាការ[98]

តាមក្រមនីតិវិធីព្រហ្មទណ្ឌពុំបានឲនិយមន័យ នៃការត្រួតពិនិត្យតាមផ្លូវតុលាការអោយបានទូលំទូលាយនោះទេ តែយើងអាចកំណត់បានថាការដាក់ឲត្រួតពិនិត្យតាមផ្លូវតុលាការនេះជាវិធានការនិរន្តរាយមួយ

---

[96] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២៣៦។

[97] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២១៨។

[98] ឌី លីឡា និងខាន់ សុខា, នីតិវិធីព្រហ្មទណ្ឌ( Criminal Procedure Law ), ទំព័រទី៩៨ និងទំព័រទី៩៩ ។

ដូចករណីនៃការឃុំខ្លួនបណ្តោះអាសន្នដែរ គ្រាន់តែវាជាវិធានមួយដែលយើងមើលទៅហាក់មានសភាពស្រាលជាង។ ម្យ៉ាងទៀតចៅក្រមស៊ើបសួរបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឲគោរពនៅកាតព្វកិច្ចមួយ ឬច្រើន[99]។

យោងតាមការពិនិត្យលើខ្លឹមសារក្រមនីតិវិធីព្រហ្មទណ្ឌ ក៏អាចសន្និដ្ឋានបានថាការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[100] គឺជាវិធានមួយដែលមានកម្មវតដាក់ជនត្រូវចោទឲ្យស្ថិត នៅក្រោមការរឹតបន្តឹងខាងសេរីភាពមួយចំនួនតាមរយៈកាតព្វកិច្ច ឬការហាមឃាត់ដែល កំណត់ដោយច្បាប់ ដែល វិធាននេះត្រូវបានចងក្រងក្រោមគោលដៅ ៤ ផ្សេងៗគ្នា ៖

-ធានានូវការបង្ហាញខ្លួនរបស់ជនត្រូវចោទ -គោរពនូវវិធានផ្សេងៗដែលសំដៅលប់បំបាត់ពីជីវិតរបស់ជនត្រូវចោទនូវធាតុមួយចំនួន -ដាក់កំហិតនូវការព្យាបាលខាងផ្នែកសង្គម និងផ្នែកវេជ្ជសាស្ត្រ -ចេញនូវបញ្ញត្តិផ្សេងៗ ដើម្បីធានាឲ្យបាននូវសិទ្ធិរបស់ជនរងគ្រោះ អាចមានការភ័ន្តច្រឡំខ្លះ ទាក់ទងទៅនឹង វិធានខាងលើនេះ ជាពិសេសត្រង់ចំណុចទី៩ នៃមាត្រា ២២៣ ដែលបញ្ញត្តិអំពីកាតព្វកិច្ចមួយ ដែលតម្រូវឲ្យជនត្រូវចោទដាក់ប្រាក់ធានា ។ ត្រង់ចំណុចនេះ មាន មតិខ្លះថាការបង្គាប់ឲ្យជនត្រូវចោទដាក់ប្រាក់ធានា គួរទាមទារឲ្យមានស្ថាប័នជំនាញធ្វើការវាយតម្លៃទៅ លើកាលៈទេសៈ មួយចំនួនដែលពាក់ព័ន្ធទៅនឹងបទល្មើសដែលបានកើតឡើង ដើម្បីកំណត់អំពីចំនួនទឹក ប្រាក់ដែលត្រូវដាក់ធានានោះ ។ ជាឧទាហរណ៍ ពាក់ព័ន្ធនឹងបទបង្ករបួសដោយចេតនា គឺតម្រូវឲ្យគ្រូពេទ្យ វាយតម្លៃអំពីស្ថានភាពរបួសជាមុនសិន ដើម្បីឲ្យដឹងពីទំហំព្យសនកម្ម (ទំហំនៃសំណងការរបួស) ក្នុងគោលបំណងឲ្យជនត្រូវចោទដាក់ប្រាក់ធានាឲ្យធនល្មមនឹងសំណងផ្នែករដ្ឋប្បវេណី ព្យសនកម្មដែលកើតឡើងនោះ ។

## ការពិចារណា

**ទី១៖** គ្រប់ជនដែលត្រូវរងការចោទប្រកាន់ត្រូវបានសន្មតថាគ្មានទោស ដរាប ទាន់ប្រកាសពីពិរុទ្ធភាពជាស្ថាពរនៅឡើយ ។

**ទី២៖** តុលាការនឹងសម្រេចការជួសជុលព្យសនកម្មបាន លុះត្រាតែបានប្រកាសថា ជនជាប់ចោទត្រូវមានពិរុទ្ធជាមុនសិន ។

[99] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២២៣។

[100] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២២៣។

**ទី៣៖** ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាវិធានការនិរន្តរាយ និងមាន គោលបំណងឲ្យជនត្រូវចោទបង្ហាញខ្លួននូវគ្រប់កិច្ចនីតិវិធីស៊ើបសួរ ដើម្បីជាប្រយោជន៍នៃការស្វែងការពិត ពុំទាន់មានទិសដៅដល់ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬទណ្ឌកម្មខាងហិរញ្ញវត្ថុឡើយ ។ ត្រង់ចំណុចនេះ យើងគួរធ្វើការពិចារណាទៅលើមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន [101] បានបញ្ញត្តិអំពីភាពចាំបាច់នៃការឃុំខ្លួនបណ្ដោះអាសន្ន ឃើញថា ពុំមានចំណុចណាមួយ ដែល បញ្ញត្តិអំពីភាពចាំបាច់នៃការទទួលខុសត្រូវ ផ្នែករដ្ឋប្បវេណីនោះឡើយ ។

**ទី៤៖** ចំណុចទី៩ នៃមាត្រា២២ បានផ្ដល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរ ជាអ្នកកំណត់ដោយ ផ្អែកលើធនធានជនត្រូវចោទ ។ បទប្បញ្ញត្តិនេះ មិនបានចង្អុលបង្ហាញឲ្យចៅក្រមស៊ើបសួរកំណត់ប្រាក់ ធានាតាមទំហំនៃព្យសនកម្មនោះទេ ។

**ទី៥៖** ប្រាក់ធានានឹងអាចត្រូវបានប្រគល់ឲ្យទៅជនត្រូវចោទវិញ នៅពេលដែលចៅក្រម ស៊ើបសួរចេញដីកាដំណោះស្រាយផងដែរ ។

ទឡ្ហីករណ៍ខាងលើនេះ អាចសន្និដ្ឋានថាការយល់ឃើញក្នុងសម្មតិកម្មខាងលើនេះជាការមិនត្រឹមត្រូវ នោះទេ ពីព្រោះការបង្គាប់ឲ្យដាក់ប្រាក់ធានាខាងលើនេះ ពុំមែនជាការតម្កល់ប្រាក់ដើម្បីធានាសំណងផ្នែក រដ្ឋប្បវេណីនោះឡើយ ។

ដើម្បីនឹងអនុវត្តនូវវិធាននេះបាន ត្រូវគោរពលក្ខខណ្ឌពីរ ៖ លុះត្រាតែជនត្រូវចោទ ជាជនដែល ៖

១-មានអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ២-ត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ។

ស្របនឹងខ្លឹមសារនេះយើងអាចកំណត់បានថា ជនសង្ស័យដែលជាប់ពាក់ព័ន្ធនឹងបទល្មើស និងទណ្ឌកម្មពិន័យជាប្រាក់សុទ្ធសាធ មិនអាចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានឡើយ ។

[101] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២០៥។

### ២.៥.១ ដីកាបង្គាប់ឲដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[102]

ចៅក្រមស៊ើបសួរដាក់ឲជនត្រូវចោទឲស្ថិតនៅ ក្រោមការត្រួតពិនិត្យរបស់តុលាការតាមគំនិតផ្តើមផ្ទាល់របស់ខ្លួន ឬតាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ ។

**ដីកាសម្រេចដាក់ខ្លួនឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ** ត្រូវជូនដំណឹងក្នុង រយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និង ជនត្រូវចោទ។

កាលណាចៅក្រមស៊ើបសួរ ដែលទទួល បណ្តឹងតាមសេចក្តីសន្និដ្ឋានពីព្រះរាជអាជ្ញា សុំឱ្យ ដាក់ខ្លួនជនត្រូវចោទឱ្យ ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មិនព្រមសម្រេចតាមការសុំនោះទេ ចៅក្រមស៊ើបសួរត្រូវចេញ **ដីកាបដិសេធការសុំ** នេះ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។

ដីកាសម្រេចនេះ ត្រូវជូន ដំណឹងក្នុងរយៈពេលយ៉ាងខ្លី បំផុតដល់ព្រះរាជអាជ្ញា ។ ប្រសិនបើចៅក្រមស៊ើបសួរ មិន បានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញា អាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលសម្រេច ជំនួសចៅក្រមស៊ើបសួរ ។

### ២.៥.២ ភាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានកំណត់អំពីកាតព្វកិច្ចក្រោមការត្រួតពិនិត្យរបស់តុលាការ ។ ដោយចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឲស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ បានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនេះត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។

ការត្រួតពិនិត្យតាមផ្លូវតុលាការមានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំអោយគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ៖

១. មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ ។

២. មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។

៣. មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ ។

[102] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២២៦។

៤. ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

៥. ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

៦. ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់ពីអត្តសញ្ញាណ ។

៧. មិនត្រូវបើកបររថយន្ត ។

៨. មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ ។

៩.ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានានិងថិរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ ។

១០. មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជី នូវអាវុធដែលជនត្រូវចោទកាន់កាប់ ។

១១. ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់អោយស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២. មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។ ប៉ុន្តែចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្ត នូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងសហជីពបានទេ[103] ។

### ២.៥.៣ ការដាក់ឱ្យអនីតិជនស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[104]

ចៅក្រមស៊ើបសួរអាចដាក់អនីតិជនត្រូវចោទឲ្យ នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាជំនួសឲ្យការឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនបើអនីតិជនត្រូវចោទនោះត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។ បន្ថែមលើបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យ តាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ ៖

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយ

[103] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២២៣។

[104] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦, មាត្រា៤០។

- ឲ្យស្ថិតក្រោមការគ្រប់គ្រង និងការថែទាំនៅមណ្ឌលណាមួយរបស់រដ្ឋ ឬ មណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- បង្គាប់មិនឲ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប។

### ២.៥.៤ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ

ទោះបីជាមានការដាក់នូវកាតព្វកិច្ចក្រោមការត្រួតពិនិត្យរបស់តុលាការក៏ដោយ ប៉ុន្តែនូវមានករណីផ្សេងៗដែលអាចកែប្រែនូវកាតព្វកិច្ចក្រោមការត្រួតពិនិត្យរបស់តុលាការបានផងដែរ តួយ៉ាងមានដូចជា៖

#### ២.៥.៤.១ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយឆន្ទានុសិទ្ធិ របស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីគ្រប់ពេលវេលា ហើយក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការផងដែរ ។ សេចក្តីស ដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[105] ។

#### ២.៥.៤.២ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឲ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេល។ ចៅក្រមស៊ើបសួរត្រូវតែពិនិត្យការស្នើសុំកែប្រែរបស់ព្រះរាជអាជ្ញាព្រមទាំងត្រូវចេញសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ។ បើសិនជារយៈពេល ៥ ថ្ងៃនេះ ចៅក្រមស៊ើបសួរមិនបានសម្រេចនោះទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភា ស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ ។ ដីកាសម្រេចបដិសេធនឹងពាក្យសុំរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវតែមានសំអាងហេតុត្រឹមត្រូវសមហេតុផល និងត្រូវជូនដំណឹង ក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា[106] ។

[105] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២២៧។
[106] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២២៨។

### ២.៥.៤.៣ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឲ្យលើកលែង ឬកែប្រែនៅការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ចៅក្រមស៊ើបសួរ ត្រូវបញ្ជូនពាក្យសុំរបស់ជនត្រូវចោទនោះភ្លាម និងសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យនិងផ្ដល់យោបល់ ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។ ដីកានេះត្រូវជូនដំណឹងក្នុងពេលខ្លីបំផុតទៅព្រះរាជអាជ្ញា និងជនត្រូវចោទ ។

កាលណាមានពាក្យសុំឲ្យលើកលែង ឬឲ្យកែប្រែការត្រតពិនិត្យនេះ បានធ្វើជាថ្មីមុនពេលចៅក្រម ឧបសួរ ឬសភាស៊ើបសួរសម្រេចលើពាក្យសុំលើកមុន នោះរយៈពេល ៥ ថ្ងៃនេះត្រូវចាប់ផ្ដើមគិតពី ។លចេញសេចក្ដីសម្រេចលើពាក្យសុំពីមុន ។ ដីកាសម្រេចបដិសេធនឹងពាក្យសុំត្រូវតែមានសំអាងហេតុ[107] ។

បើសិនជារយៈពេល៥ថ្ងៃនេះកន្លងផុតទៅចៅក្រមស៊ើបសួរមិនបានសម្រេចជនត្រូវចោទអាចធ្វើពាក្យបណ្ដឹង ប្ដឹងផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ ។

### ២.៥.៥ ការគេចវេសពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ប្រសិនបើជនត្រូវចោទ បានគេចវេសដោយចេតនាពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផត ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នបាន ទោះក្នុងករណីដែល ៖

-ទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ (មានន័យថាលក្ខណមាត្រា ២០៤ លែងជាឧបសគ្គនៃការឃុំខ្លួនបណ្ដោះអាសន្នទៀតហើយ) ។

-ជនត្រូវចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេលអតិបរមានៃថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមមាត្រា ២០៨, ២០៩, ២៩០, ២១៣ និង២១៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-កាលណាសម្រេចថា នឹងឃុំខ្លួនបណ្ដោះអាសន្នដោយមូលហេតុខាងលើនេះចៅក្រមស៊ើបសួរត្រូវជូនដំណឹង ដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ ហើយត្រូវឲ្យមេធាវីជូន មធ្យោបាយការពារ បើសិនជាមានមេធាវីអមជងនោះ ។

-ដីកាសម្រេចត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។

[107] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២២៩។

-ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវឃុំឡើងដោយមិនអាច ឲ្យលើស ពី ៤ ខែ ចំពោះនីតិជន និងមិនអាចលើសពី ២ ខែ ចំពោះអនីតិជនឡើយ[108] ។

-ការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវបានបញ្ចប់នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចរក្សាទុកជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួត ពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលបង្ហាញខ្លួននៅចំពោះមុខតុលាការនោះទេ[109]។

-ការត្រួតពិនិត្យតាមផ្លូវតុលាការ ក៏ត្រូវបញ្ចប់នៅពេលដែលតុលាការប្រកាសសាលក្រមដើរ (មាត្រា ៣៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)[110] ។

[108] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២៣០។

[109] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២៤៩,កថាខណ្ឌទី៤ និងទី៦។

[110] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា២៣០។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវយ៉ាងស៊ីជម្រៅរួចមក ឃើញថានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានធ្វើការបញ្ញត្តិ ក៏ដូចជាការតាក់តែងឡើងនូវនីតិវិធី ឬ បទដ្ឋានគតិយុត្តផ្សេងៗគ្នាដើម្បីធ្វើការអនុវត្ត។ ការធ្វើបែបនេះ ក៏ព្រោះដើម្បីស្វែងរកអោយឃើញនូវអត្ថិភាពនៃបទល្មើសយ៉ាងពិតប្រាកដ ដោយអង្គនីតិបញ្ញត្តិបានធ្វើការបែងចែកជាដំណាក់កាលផ្សេងៗពីគ្នា ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាពីដំណើរការទៅតាម ដំណាក់កាលនីមួយៗដូចជា ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលនៃការជំនុំជម្រះ។ ដោយឡែកនៅក្នុងការសិក្សានៃអត្ថបទសារណានេះយើងធ្វើការសិក្សានៅក្នុងដំណាក់កាលនៃ ចៅក្រមស៊ើបសួរដោយជ្រើសយកតែផ្នែកតូចមួយនៃដំណាក់កាលចៅក្រមស៊ើបសួរតែប៉ុណ្ណោះគឺ **ការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ** ។

ដូចដែលបានអធិប្បាយ ឬលើកឡើងនៅអត្ថបទខាងលើនេះ យើងអាចសន្និដ្ឋានបានថា តួនាទីចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលនៃការស៊ើបសួរ គឺដើម្បីស្វែង រកភាពពិតប្រាកដ និងស្វែងរកភស្តុតាងនៃសំណុំរឿងព្រហ្មទណ្ឌ ដើម្បីឲមានតម្លាភាព និងសុក្រឹត្យភាព ដោយរក្សា បាននូវស្ថិរភាពនៃនីតិវិធីក្នុងរឿងក្តី គោរពបាននូវសិទ្ធិរបស់បុគ្គលពាក់ព័ន្ធ ព្រមទាំងបានផ្តល់នូវ ភស្តុតាងយ៉ាងប្រត្យក្សចំពោះអង្គហេតុដែលបានកើតឡើង។ ការឃុំខ្លួនបណ្តោះអាសន្ន ដែលមាន ចែងនៅក្នុងក្រមនីតិវិធី គឺជាវិធានការនិរន្តរាយមួយក្នុងចំណោមវិធានផ្សេងៗទៀតដែលអនុញ្ញាតអោយ ចៅក្រមស៊ើបសួរ អាចធ្វើទៅបានក្នុងគោលបំណងដើម្បីធានានៅកិច្ចនៃការស៊ើបសួររបស់ខ្លួនប្រព្រឹត្តទៅបានដំណើរការល្អប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការស្វែងរកអោយឃើញពីអត្ថិភាពនៃអង្គហេតុបង្ហាញអោយឃើញពីពិរុទ្ធភាពរបស់ជនត្រូវចោទ។ បើទោះបីជាចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ ដោយស៊ើបសួរទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ប៉ុន្តែការឃុំខ្លួនបណ្តោះអាសន្ននៅតែជាការចាំបាច់។ ការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទមិនមែនមានន័យថាជននោះមានទោសនោះទេ ពីព្រោះថាវាគ្រាន់តែជាវិធានការដើម្បីឃាត់ជនត្រូវចោទអោយនៅក្នុងពន្ធនាគារដើម្បីរកអោយឃើញថាជននោះមានទោស ឬគ្មានតែប៉ុណ្ណោះ។ បន្ថែមពីនេះ លុះត្រាតែមានការប្រកាសជាស្ថាពរ ដោយសាលក្រម ឬសាលដីកាជាស្ថាពរពីតុលាការប៉ុណ្ណោះទើប អាចបញ្ជាក់ថាជនណាម្នាក់មានទោសពីបទល្មើស ណាមួយ ហើយជននោះអាចមានសេរីភាពវិញបាន។

ស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ននេះ ចៅក្រមស៊ើបមានតួនាទីក្នុងការសួរព្រមទាំងធ្វើការពិចារណា ក៏ដូចជាធ្វើការសាកសួរព័ត៌មានពីជនត្រូវចោទអោយបានគ្រប់ជ្រុងជ្រោយមុនសិន ដើម្បីយកធ្វើជាសំអាងហេតុ

គតិយុត្ត មុននឹងឈានទៅដល់ការសម្រេចការឃុំខ្លួនបណ្តោះ អាសន្ន។ ទន្ទឹមនឹងនេះផងដែរ ចៅក្រមស៊ើបសួរគប្បីពិនិត្យអំពីលក្ខខណ្ឌមួយចំនួនដែលត្រូវបាន កំណត់ដោយច្បាប់ជាធរមានក្នុងគោលដៅធានាអោយបាននីត្យានុកូលភាពនៃការឃុំខ្លួនបណ្តោះអាសន្ន ។

ទោះបីជាគោលការណ៍សេរីភាពត្រូវបានទទួលស្គាល់ និងយកមកអនុវត្តប៉ុន្តែនៅក្នុងករណីចាំបាច់ ការឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរ គប្បីពិនិត្យនូវលក្ខខណ្ឌមួយចំនួនដែលទាក់ទិន ទៅនឹងការឃុំខ្លួនបណ្តោះអាសន្នដូចជា លក្ខខណ្ឌទាក់ទងទៅនឹងបទល្មើសដែលត្រូវបានចោទប្រកាន់ លក្ខខណ្ឌទាក់ទងទៅនឹងទោស ព្រមទាំងលក្ខខណ្ឌទាក់ទងទៅនឹងអាយុរបស់ជនត្រូវចោទ ដែលលក្ខខណ្ឌទាំងនេះគឺជាចំណុចសំខាន់សម្រាប់ចៅក្រមស៊ើបសួរ ត្រូវតែដឹងដោយហេតុអាយុនេះជាមូលដ្ឋាន យ៉ាងសំខាន់ក្នុងការសម្រេចពីការឃុំខ្លួន និងរយៈពេលនៃការឃុំខ្លួនដែលត្រូវបានកំណត់ដោយក្រម នីតិវិធីព្រហ្មទណ្ឌ។ អ្វីដែលជាចំណុចពិសេសជាងនេះទៅទៀតនោះ ការឃុំខ្លួនបណ្តោះអាសន្នទៅ លើជនត្រូវចោទមានអាយុតិចជាង១៥(ដប់ប្ដូន) ឆ្នាំ មិនត្រូវបានអនុញ្ញាតនោះឡើយ ។

លើសពីនេះទៅទៀតចៅក្រមស៊ើបសួរ ត្រូវតែឲជនត្រូវចោទធ្វើតាមដំណើរការនៃនីតិវិធីសម្រេចឲឃុំខ្លួនបណ្តោះអាសន្ន ពោលគឺធ្វើការបង្ហាញខ្លួនជាលើកដំបូងចំពោះ ជនត្រូវចោទដោយអាចមានវត្តមានរបស់តំណាងអយ្យការ និងមេធាវីការពារសិទ្ធិអោយជនត្រូវចោទ ប្រសិនបើមាន ក្នុងគោលបំណងដើម្បីធ្វើការផ្ទៀងផ្ទាត់ពីអត្តសញ្ញាណរបស់ជនត្រូវចោទ ជៀសវាង នៅការភ័ន្តច្រឡំណាមួយដែលអាចកើតមានឡើងជាយថាហេតុ។ ទន្ទឹមនឹងការបង្ហាញខ្លួនជាលើក ដំបូងចៅក្រមស៊ើបសួរត្រូវធ្វើការពិភាក្សាដេញដោលចំពោះមុខក្នុងការសាកសួរពីព័ត៌មានមួយចំនួន ដែលយល់ឃើញថាជាការចាំបាច់ក្នុងការសម្រេចពីការឃុំខ្លួន ឬមិនឃុំខ្លួនបណ្តោះអាសន្នលើ ជនត្រូវចោទ ។

ក្រោយពីការបញ្ចប់កិច្ចទាំងពីរនេះរួចហើយ ប្រសិនបើចៅក្រមស៊ើបសួរគាត់យល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នជាការចាំបាច់ គាត់ត្រូវតែបង្ហាញពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលជាមូលហេតុទូទៅ ឬក៏មូលហេតុពិសេសដែលជា ការគេចវេសពីការត្រួតពិនិត្យតាមផ្លូវតុលាការ។ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវធ្វើដីកាសម្រេចឃុំខ្លួន បណ្តោះអាសន្ន និងចេញដីកាបង្គាប់អោយឃុំខ្លួនទៅលើជនត្រូវចោទដែលជាកម្មវត្ថុនៃការឃុំខ្លួន ។

សរុបសេចក្តីមក ការឃុំខ្លួនបណ្តោះអាសន្នដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ មានលក្ខណៈកាត់បន្ថយនូវសិទ្ធិសេរីភាពរបស់ជនត្រូវចោទ ប៉ុន្តែក៏អាចបកស្រាយបានថាការអនុវត្ត វិធាននេះគឺធ្វើឡើងក្នុងគោលបំណងរក្សាសុវត្ថិភាព និងសន្តិសុខចំពោះជនត្រូវចោទ ក៏ដូចជាបង្កាការពារជនត្រូវចោទមិនឲទៅបង្ក ឬ ប្រព្រឹត្តនៅបទល្មើសផ្សេងទៀត ដែលនាំឲមានផលប៉ះពាល់បន្ថែមទៀតទៅដល់ជនដទៃទៀត រួមទាំងផលប្រយោជន៍សាធារណៈ និងសណ្តាប់ធ្នាប់សង្គមជាតិផងដែរ។ ម៉្យាងវិញទៀតការធ្វើបែបនេះវាពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងកិច្ចដំណើរការនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរដើម្បីស្វែងរក យុត្តិធម៌ជូនជនរងគ្រោះ ឬ សង្គម និងបង្ហាញពីការរក្សាបាននូវស្មារតីនៃរដ្ឋធម្មនុញ្ញដែលមានតែស្ថាប័នតុលាការមួយប៉ុណ្ណោះដែលមានសិទ្ធិក្នុងការសម្រេចសេចក្តី។

# អនុសាសន៍

# អនុសាសន៍

ឆ្លងកាត់ការសិក្សាស្រាវជ្រាវ និងតាមរយៈការសាកសួរមន្ត្រីដែលអនុវត្តច្បាប់នៅសាលាដំបូងរួចមក យើងសង្កេតឃើញថា **វិធានការនៃការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ** ពុំសូវត្រូវបានប្រើឱ្យបាន ទូលំទូលាយស្របតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌនៅឡើយទេ ហើយជាទូទៅចៅក្រមស៊ើបសួរបាន ប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសម្រេចជ្រើសយក ការឃុំខ្លួនបណ្ដោះអាសន្ន ជាវិធានការនិរន្តរាយ ដើម្បីធានាដល់ដំណើរការ នៃការស៊ើបសួរដែលជាកត្តារួមចំណែក នាំឱ្យមានការកើនឡើង នៃ ជនជាប់ឃុំនៅតាមពន្ធនាគារ ។ ចៅក្រមស៊ើបសួរ គប្បីយកចិត្តទុកដាក់ប្រើឆន្ទានុសិទ្ធិ របស់ខ្លួនក្នុងការអនុវត្តឱ្យបានត្រឹមត្រូវ ស្របតាមមាត្រា ២០៣ និង មាត្រា ពាក់ព័ន្ធបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន។ ជាពិសេសស្មារតីនៃការគោរព **គោលការណ៍សេរីភាពជាចម្បង** និង **គោលការណ៍សន្មតទុកជាមុនថាគ្មានទោស។** ហេតុដូចនេះគប្បីមានការកែតម្រូវនូវចំណុចមួយចំនួនក្នុងគោលបំណងដើម្បី ឲ្យការអនុវត្តន៍កាន់តែមានប្រសិទ្ធភាពតាមការកំណត់ក្នុងទ្រឹស្តី នឹងទទួលបានទំនុកចិត្តពីសាធារណៈជន ក៏ដូចជាជនត្រូវចោទ យើងខ្ញុំសូមលើកយកអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

- ធានាអោយបានគោលការណ៍សេរីភាពរបស់ជនត្រូវចោទ ពោលគឺជៀសវាងនៅក្នុងករណីមួយចំនួន ដែលការឃុំខ្លួនបណ្ដោះអាសន្នមិនមែនជាការចាំបាច់ ។
- ទាក់ទិនកិច្ចបង្ហាញខ្លួនលើកដំបូងគួរតែធ្វើដាច់ដោយឡែក ហើយត្រូវប្រាប់ពីសិទ្ធិដែល ធានាដោយក្រមនីតិវិធីព្រហ្មទណ្ឌទាំងអស់ដល់ជនត្រូវចោទ ដើម្បីឲ្យគាត់មានលទ្ធភាព ការពារខ្លួនតាមការកំណត់របស់ច្បាប់ ។
- នីតិវិធីនៃការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន គួរអនុវត្តឲ្យបានត្រឹមត្រូវតាមការ កំណត់នៅក្នុងទ្រឹស្តី ដោយ ទី១-ត្រូវធ្វើកិច្ចបង្ហាញខ្លួនលើកដំបូង, ទី២-កិច្ចពិភាក្សាដេញ ដោលចំពោះមុខ និងទី៣-ទើបឈានដល់ការសម្រេចពីការឃុំខ្លួនបណ្ដោះអាសន្នលើការ ឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទ ។ ចៅក្រមស៊ើបសួរក្រោយពីទទួលបានសំណុំរឿងព្រហ្មទណ្ឌ ដែលត្រូវបានចាត់តាំងដោយ ប្រធានតុលាការដោយដីកាសម្រេចចាត់តាំងចៅក្រមស៊ើបសួរ ត្រូវដំណើរការនៃនីតិវិធី បង្ហាញខ្លួនជាលើកដំបូង និងធ្វើការពិភាក្សាដេញដោលចំពោះមុខព្រោះថានីតិវិធីនេះ គឺ មានភាពចាំបាច់បំផុតដោយហេតុចៅក្រមស៊ើបសួរអាចស្វែងយល់ និងដឹងពីព័ត៌មាន បន្ថែមអំពីជនត្រូវចោទក្នុងការវិនិច្ឆ័យថាតើខ្លួនត្រូវសម្រេចឃុំខ្លួនជនត្រូវចោទ ឬ មិនឃុំ។

- ចំពោះកិច្ចពិភាក្សាដេញដោលចំពោះមុខ គួរបើកជាសវនាការមុនអង្គសេចក្តីមួយនៅ សាលសវនាការជាសាធារណៈហើយធ្វើយ៉ាងណាត្រូវធានាឲ្យបាននូវវត្តមានរបស់ភាគី ពាក់ព័ន្ធចូលរួម ទាំងតំណាងអយ្យការ មេធាវី និងជនត្រូវចោទ ដើម្បីធ្វើការពិភាក្សាដេញ ដោលតទល់ពីមូលហេតុ ក៏ដូចជាលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន។ ម៉្យាងទៀតវា នឹងធ្វើឲ្យជនត្រូវចោទអស់ចិត្ត និងទទួលយកចំពោះសេចក្តីសម្រេចឃុំខ្លួនដែលចេញ ដោយចៅក្រមស៊ើបសួរ មិនតែប៉ុណ្ណោះ វានឹងធានាបានថាប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌត្រូវ បានអនុវត្តយ៉ាងត្រឹមត្រូវចំពោះជនត្រូវចោទ ។
- ដើម្បីធានាឲ្យបាននូវសវនាកាមុនអង្គសេចក្តីប្រព្រឹត្តទៅឲ្យបានរលូន ដោយសារតែបញ្ហា កកស្ទះសំណុំរឿងច្រើនពេកនៅតាមសាលាដំបូងនីមួយៗ គួរបន្ថែមចំនួនចៅក្រម និងព្រះ រាជអាជ្ញា ដើម្បីមានពេលវេលាគ្រប់គ្រាន់ធ្វើចំណាត់ការសំណុំរឿងត្រឹមត្រូវតាមការកំណត់ ក្នុងនីតិវិធីច្បាប់ ។
- ចំពោះទ្រឹស្តីទាក់ទងនឹងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ គួរតែកំណត់ ឲ្យបានច្បាស់លាស់អំពីនីតិវិធីនៃការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ជាពិសេសនីតិវិធីនៃ ការសម្រេចឃុំខ្លួនបណ្តោះអាសន្ន នៅពេលពេលជនត្រូវចោទត្រូវបានយកមកបង្ហាញខ្លួន នៅចំពោះមុខចៅក្រមស៊ើបសួរបន្ទាប់ពីបានបំពាននឹងកាតព្វកិច្ចដាក់ឲ្យស្ថិតនៅក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការ ។

ក្រៅពីនេះ ក្រោយពេលដែលចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជន ត្រូវចោទរួចហើយ ជននោះត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅក្នុងពន្ធនាគារដើម្បីរងចាំការកាត់ក្តី ដោយចៅក្រមជំនុំជម្រះ។ ទន្ទឹមនឹងនោះខ្ញុំបាទយល់ឃើញថា៖

- ជនត្រូវចោទដែលត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារនោះ គឺមានភាពខ្វះខាតនៅជំនួយផ្នែកច្បាប់ ហើយពេលខ្លួនពួកគាត់ក៏មានជីវភាពខ្វះខាតដែលធ្វើអោយគាត់គ្មានលទ្ធភាពក្នុងការ ប្រើប្រាស់សិទ្ធិរបស់គាត់តាមផ្លូវច្បាប់ ដូចជាសិទ្ធិក្នុងការស្នើសុំនៅក្រៅឃុំ សិទ្ធិក្នុងការប្តឹង ជិតចិត្ត សិទ្ធិក្នុងការប្តឹងទៅនឹងដីកាផ្សេងៗរបស់ចៅក្រមស៊ើបសួរដែលច្បាប់បានផ្តល់ជូន គាត់។
- គួរការពន្លឿននីតិវិធី ចៅក្រមស៊ើបសួរគួរផ្តល់អាទិភាពចំពោះសំណុំរឿងព្រហ្មទណ្ឌ ទាំងឡាយណាដែលមានជនត្រូវចោទ ដែលនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នជាពិសេស គឺ សំណុំរឿងដែលមានជនត្រូវចោទជាអនីតិជនជាដើម ព្រមទាំងធានាឲ្យមានការសហការ បានល្អជាមួយស្ថាប័នដែលពាក់ព័ន្ធនៅក្នុងនីតិវិធីនៃការស៊ើបសួរ ។

ទោះបីជាមានការចន្លោះប្រហោងខ្លះៗក្នុងនីតិវិធីដំណាក់កាលឃុំខ្លួនបណ្ដោះអាសន្ន ក៏ប៉ុន្តែប្រសិនបើមានការកែតម្រូវនូវចំណុចមួយចំនួន នោះដំណើរការសំណុំរឿងនីមួយៗឲ្យបានលឿន និងប្រកបដោយប្រសិទ្ធភាព ដែលជាហេតុនាំឲ្យយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងតាមតុលាការ ទទួលបានជោគជ័យ។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ២៤ កញ្ញា ១៩៩៣។
- ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ ។
- ច្បាប់ស្តីពីវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២៤៧ មាត្រា៣៧២ និងមាត្រា៣៨២,នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ០៩ មិថុនា ២០១៣ ។
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦ ។
- ច្បាប់ស្តីពីពន្ធនាគារ, ៧ វិច្ឆិកា ២០១១ ។

## ២. លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សប្រទេសបារាំង, ឆ្នាំ១៧៨៩។
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, ១០ ធ្នូ ១៩៤៨។
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី២៦ ឧសភា ឆ្នាំ១៩៤៨។

## ៣. សៀវភៅ និងឯកសារផ្សេងៗ

- លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។
- សេចក្តីណែនាំលេខ ១២០ កយ.រប/១៤ របស់ក្រសួងយុត្តិធម៌( 1.ស្ថានភាពអង្គហេតុ និងអង្គច្បាប់ ) ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤។
- សន្និសីទស្តីពី ការណែនាំពីការអនុវត្តដីការសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងសារាចរនានាស្តីពីជម្រើសផ្សេងទៀត ក្រៅពីការឃុំខ្លួន ចុះថ្ងៃទី ២៥-២៦ ខែមីនា ឆ្នាំ ២០១៤ ។
- Presumption of innocence (គោលការណ៍សន្មតថាគ្មានទោស) បកប្រែដោយ Cambodia Law Insider ចុះថ្ងៃទី១៨ មេសា ឆ្នាំ២០២១។
- ជួន សុរាសី, នីតិវិធីសង្ខេប: រដ្ឋប្បវេណី និងព្រហ្មទណ្ឌ, ឯកសារចម្លង ២០១១។
- វ៉ាន់ ច័ន្ទតារា, នីតិសិទ្ធមនុស្ស Human Right Law, ភ្នំពេញ, បោះពពុម្ភ ឆ្នាំ២០១៤។
- ហែល ចំរើន, មរតកយុត្តិធម៌ខ្មែរ (ភ្នំពេញ៖ បោះពុម្ពផ្សាយដោយរោងពុម្ភ ភ្នំពេញ, ឆ្នាំ២០១០ ។
- ឌី លីឡា និងខាន់ សុខា, នីតិវិធីព្រហ្មទណ្ឌ( Criminal Procedure Law )។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| *ល.រ* | *ឈ្មោះឯកសារ* |
|---|---|
| ០១ | ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ |
| ០២ | កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង |
| ០៣ | កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ |
| ០៤ | កំណត់ហេតុសួរចម្លើយជនត្រូវចោទ |
| ០៥ | ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន |
| ០៦ | ដីកាបង្គាប់ឲ្យឃុំខ្លួន |
| ០៧ | ពាក្យសុំនៅក្រៅឃុំខ្លួនបណ្តោះអាសន្ន |
| ០៨ | ដីកាបញ្ជូនឲ្យឆ្លើយ |
| ០៩ | ដីកាសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន |
| ១០ | ដីកាបង្គាប់ឲ្យដោះលែង |
| ១១ | ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន |
| ១២ | ដីកាសម្រេចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ |
| ១៣ | ដីកាបង្គាប់ឲ្យចាប់ខ្លួន |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌ

**ឧបសម្ព័ន្ធ១**

លេខ [redacted] ថ្ងៃទី២៧.០៣.២០២២

លេខ [redacted] ............ អ.យ.ឆ

## <u>ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ</u>

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ របាយការណ៍សំយោគលេខ ០៤៩/២២ រ.ប.ក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ របស់ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ ។

### <u>ក្រោយពីបានពិនិត្យឯកសារខាងលើ</u>

*យល់ឃើញថា មានតម្រុយសន្មត ៖*

-.នាមត្រកូល និងនាមខ្លួន[1]៖ [redacted] ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ (ឆ្នាំកំណើត [redacted]) សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរលក់ម្ហូបតាមOnline ទីកន្លែងកំណើតនៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួលបុរីប៉េងហួត បឹងស្នោ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ស្លាប់ ម្ដាយឈ្មោះ [redacted] ស្លាប់ ជានីតិជន ទោសពីមុនគ្មាន ។ *(ឃាត់ខ្លួន)*

ប្រព្រឹត្តអំពើដូចតទៅ[2] ៖ កាលពីឆ្នាំ២០២០ ឈ្មោះ [redacted] ភេទប្រុស អាយុ ៣៣ឆ្នាំ បានខ្ចីប្រាក់ពីឈ្មោះ ហោយ រស្មី ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) ដើម្បីយកទៅរកស៊ី ហើយឈ្មោះ ពៅ ចាន់ទី បានខ្ចីប្រាក់ពីឈ្មោះ ប៉ែន មរកត ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) ដោយកំណត់សងនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ លុះដល់ថ្ងៃកំណត់សងប្រាក់ ឈ្មោះ ពៅ ចាន់ទី បានចេញមូលប្បទានបត្ររបស់ធនាគារ [redacted] ទៅឲ្យឈ្មោះ ហោយ រស្មី ចំនួន ២សន្លឹក មួយសន្លឹកលេខ ៥១៩១៤៤ មានទឹកប្រាក់ចំនួន ២០,០០០$ (ពីរម៉ឺនដុល្លារអាមេរិក) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ មួយសន្លឹកទៀតលេខ ៥១៩១៣៥ មានទឹកប្រាក់ចំនួន ៣០,០០០$ (បីម៉ឺនដុល្លារអាមេរិក) ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ និងចេញមូលប្បទានបត្រមួយសន្លឹកទៅឲ្យឈ្មោះ [redacted] លេខ ៥១៩១៣៤ មានទឹកប្រាក់ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ។ លុះដល់ថ្ងៃកំណត់បើកប្រាក់

[1] [illegible]
[2] [illegible]

ឈ្មោះ បោយ រស្មី និងឈ្មោះ បានយកមូលប្បទានបត្រទៅបើកប្រាក់នៅធនាគារ ស្រាប់តែខាងធនាគារបានបញ្ជាក់ថាមូលប្បទានបត្រគឺពុំមានសាច់ប្រាក់នោះទេ បន្ទាប់មក ឈ្មោះ បោយ រស្មី និងឈ្មោះ ប៉ែន មរកត ក៏បាននាំខ្លួនឈ្មោះ ពៅ ចាន់ទី មកប្រគល់ជូន សមត្ថកិច្ចដើម្បីចាត់ការតាមនីតិវិធីតែម្តង ។

អំពើប្រព្រឹត្តខាងលើជាបទល្មើស មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

**<u>សម្រេច</u>**

*បើកការស៊ើបសួរលើអង្គហេតុខាងលើ ៖*

☑ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ[៣] ៖

-.ឈ្មោះ ភេទប្រុស អាយុ ៣៣ឆ្នាំ ។ (ឃាត់ខ្លួន)

ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

☐ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៤] ៖ ..........................................

..........................................................................................................

☑ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[៥] ៖

-.ឈ្មោះ ភេទប្រុស អាយុ ៣៣ឆ្នាំ ។ (ឃាត់ខ្លួន)

ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

ថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២

**ចៅក្រមស៊ើបសួរ**

[៣] ឈ្មោះជនត្រូវចោទ

[៤] ការត្រួតពិនិត្យតាមផ្លូវតុលាការ ... មាត្រា ២២៣

[៥] ការឃុំខ្លួនបណ្តោះអាសន្ន ... មាត្រា ២០៥

**ឧបសម្ព័ន្ធ២**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

ចៅក្រម (ឃ)

## កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

សំណុំរឿងព្រហ្មទណ្ឌលេខ ____

ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២២ (មាត្រា ១៤៣,១៤៤,២៤០ និងមាត្រា២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ស៊ើបសួរលេខ ១១៥៩

ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២

ឆ្នាំពីរពាន់ម្ភៃពីរ ខែមីនា ថ្ងៃទីម្ភៃប្រាំបួន វេលាម៉ោងដប់មួយព្រឹក

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោកស្រី ជាក្រឡាបញ្ជី។

បុគ្គលដែលនៅចំពោះមុខយើងបានផ្តល់ព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម:

ឈ្មោះ ហៅហេង ភេទប្រុស ជនជាតិខ្មែរ មុខរបរ

ទីកន្លែងកំណើតសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះជួលនៅបុរីប៉េងហួតបឹងស្នោ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ ផាច ស៊ីណាន (រ) ជានីតិជន ទោសពីមុនគ្មាន ។

☐ជននេះបានប្រកាសប្រាប់ថាខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម១០(ដប់)ឆ្នាំដែលស្ថិតនៅ

☐ ជននេះប្រាប់ថា៖ ☐ ចេះនិយាយ ☐ ចេះអាន ☐ ចេះសរសេរអក្សរខ្មែរ

☐ ជននេះប្រាប់ថា៖ ☐ មិនចេះនិយាយ ☐ មិនចេះអាន ☐ មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងក្តី ដែលព្រះរាជអាជ្ញាបានប្តឹងសុំមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១១៥៧ អយក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ដែលជាហេតុនាំឲ្យមានការបង្ហាញខ្លួន ជននេះនៅចំពោះមុខយើង ព្រមទាំងប្រាប់ជននេះឲ្យដឹងអំពីបទចោទប្រកាន់ចំពោះរឿងក្តីដូចខាងក្រោម ៖

........................................................................................................................................................................................................

☐ យើងបានជូនដំណឹងដល់ជននេះថា យើងគ្រោងនឹងដាក់ជននេះឲ្យស្ថិតនៅក្រោមការពិនិត្យ ចំពោះរឿងក្តី ដែលយើងទើបនឹងរៀបរាប់ឲ្យជននេះដឹងយ៉ាងច្បាស់។

☐ លោក ជាមេធាវី នៃជនត្រូវចោទ ដែលបានកោះហៅនៅថ្ងៃទី.................ខែ.....................ឆ្នាំ.................ហើយដើម្បីឲ្យលោក/លោកស្រីជាមេធាវី អាចត្រៀមរៀបចំការពារកូនក្តីខ្លួនបាន។

☐ យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើសពីងមេធាវី ដោយខ្លួនឯង ឬអាចសុំឲ្យគេចាត់តាំងមេធាវីណាម្នាក់ឲ្យរបស់គាត់។

ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

- គាត់ត្រូវគាត់ត្រូវប្រកាសអំពីអាសយដ្ឋានដែលអាចជាអាសយដ្ឋានផ្ទាល់ខ្លួន ឬជាអាសយដ្ឋានរបស់តតីយជនណាម្នាក់ ដែលទទួលបន្ទុកទទួលយកលិខិតដែលបញ្ជូនទៅឲ្យគាត់ប្រសិនបើគាត់អាចផ្តល់ឲ្យបានភ្លាមនូវការព្រមព្រៀងជាលាយល័ក្ខណ៍អក្សររបស់តតីយជននោះ។
- អាសយដ្ឋានដែលត្រូវប្រកាសប្រាប់ត្រូវមានទីតាំងស្ថិតនៅ..........................................................................................................................................

អាសយដ្ឋាននេះជា □ អាសយដ្ឋានផ្ទាល់ខ្លួន
□ អាសយដ្ឋានរបស់៖..........................................................................................................................................

□ យើងបានប្រាប់ដល់ជនត្រូវចោទបន្ថែមថា៖

- រហូតដល់ការបិទការស៊ើបសួរ គាត់ត្រូវប្រាប់ដល់យើងគ្រប់ការផ្លាស់ប្តូរ អាសយដ្ឋានដែលត្រូវបានប្រកាសប្រាប់ខាងលើ ដោយការប្រកាសជាថ្មី ឬដោយលិខិតអនុសិដ្ឋ។
- គ្រប់ការជូនដំណឹង ឬការឲ្យដំណឹងដែលបញ្ជូនទៅអាសយដ្ឋានដែលបានប្រកាសប្រាប់ចុងក្រោយបង្អស់ត្រូវចាត់ទុកថា ជូនដំណឹងដល់បុគ្គលជនត្រូវចោទ។

□ យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើសិនមិនបដិសេធត្រង់ចំណុចណាទេឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

□ បានអានឲ្យស្តាប់ចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើងនិងក្រឡាបញ្ជី។

□ បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ។

| ជនត្រូវចោទ | មេធាវី | ក្រឡាបញ្ជី | ចៅក្រមស៊ើបសួរ |
|---|---|---|---|
| | | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធ៣**

សាលាដំបូងរាជធានីភ្នំពេញ

ចៅក្រមបន្ទប់ (ឃ)

សំណុំរឿងព្រហ្មទណ្ឌលេខៈ
ចុះថ្ងៃទី២៧.៣ .២០២២

ស៊ើបសួរលេខ ៈ
ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២២

## កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ

(មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ពីរាន់ម្ភៃពីរ ខែមីនា ថ្ងៃទី ម្ភៃប្រាំបួន វេលាម៉ោងដប់មួយព្រឹក

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោកស្រី ជាក្រឡាបញ្ជី។

តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ អ.យ.ឆ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានមកបង្ហាញខ្លួនក្នុងដំណាក់កាលស៊ើបសួរនៅចំពោះមុខយើងជនដែលមានពត៌មានអត្តសញ្ញាណដូចខាងក្រោម:

| |
|---|
| ឈ្មោះ ហៅហេង ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរតាមonline ទីកន្លែងកំណើតសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះជួលនៅបុរីប៉េងហួតបឹងស្នោ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) នៅលីវ ជានីតិជនទោសពីមុនគ្មាន ។ |

☐ ជននេះប្រាប់ថា៖ ☐ ចេះនិយាយ ☐ ចេះអាន ☐ ចេះសរសេរអក្សរខ្មែរ

☐ ជននេះប្រាប់ថា[1]៖ ☐ មិនចេះនិយាយ ☐ មិនចេះអាន ☐ មិនចេះសរសេរអក្សរខ្មែ

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ: មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន យោងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១១៥៧ អយឆ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២២ ។

☐ដោយមានវត្តមានមេធាវី ឈ្មោះ និងលោក ដែលជនត្រូវចោទបានជ្រើសរើសពឹងពាក់ដោយខ្លួនឯង ឬដែលត្រូវបានចាត់តាំងដោយគណៈមេធាវីនៃព្រះរាជាណា

ចក្រកម្ពុជាបានមកបង្ហាញខ្លួននៅក្នុងបន្ទប់នៅចំពោះមុខយើងបន្ទាប់ពីបានពិគ្រោះមើលសំណុំរឿងនិងបានធ្វើ ទំនាក់ទំនងដោយសេរីជាមួយជនត្រូវចោទ នៅពេលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខយើង។

[1] ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

**ឧបសម្ព័ន្ធ៤**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**
**ចៅក្រម បន្ទប់ "ឃ"**
សំណុំព្រហ្មទណ្ឌលេខ:
ចុះថ្ងៃទី២៧.៣. ២០២២
ស៊ើបសួរលេខ
ចុះថ្ងៃទី២៨.០៣. ២០២២

## កំណត់ហេតុ ស្ដីពីការសួរចម្លើយជនត្រូវចោទ

(មាត្រា ១៤៥ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃពីរ ខែមីនា ថ្ងៃទីម្ភៃប្រាំបួន វេលាម៉ោង ដប់មួយព្រឹក

យើ. ចៅក្រមសាលាដំបូងជាចៅក្រមស៊ើបសួរ អមដោយលោកស្រី ជាក្រឡាបញ្ជី ។

បានបង្ហាញខ្លួនក្នុងនាមជាជនត្រូវចោទនៅមន្ទីរស៊ើបសួរចំពោះយើង ជនមានអត្តសញ្ញាណ ដូចខាងក្រោម:

ឈ្មោះ ហៅហេង ភេទប្រុស ជនជាតិខ្មែរ មុខរបរលក់ដូរតាមonline ទីកន្លែងកំណើតសង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះជួលនៅបុរីប៉េងហួតបឹងស្នោ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោ (រ) ជានីតិជន ទោសពីមុនគ្មាន ។

□.នីតិជន ឬ □.អនីតិជន

ជននេះប្រាប់ថា: □ចេះនិយាយ □ចេះអាន □ចេះសរសេរអក្សរខ្មែរ

ជននេះប្រាប់ថា: □ មិនចេះនិយាយ □មិនចេះអាន □មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនត្រូវចោទនេះយើងបានប្រាប់ជននេះឲ្យដឹងយ៉ាងច្បាស់ អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្ដឹងសុំមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរលេខ អ.យ.ឆ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២២ ។

ជនត្រូវចោទអមដោយលោក និងលោ ជាមេធាវីការពារសិទ្ធិ ។

ស.ឆ: ខ្ញុំបានស្គាល់ដើមបណ្ដឹងឈ្មោះ និងប្រពន្ធគាត់ឈ្មោះ .... រយៈពេលយូរមកហើយតាមរយៈមិត្តភក្ដិ។

ស.ឆ: នៅអំឡុងឆ្នាំ២០១៩ ខ្ញុំបានសហការគ្នាជាមួយដើមបណ្ដឹង ដើម្បីរកស៊ីចងការប្រាក់ សរុបជាទឹកប្រាក់ចំនួន ៨ម៉ឺនដុល្លារ និងបូកទាំងការប្រាក់ចំនួន ២ម៉ឺនដុល្លារអាមេរិក បូករួមទាំងអស់ចំនួន ១០ម៉ឺនដុល្លារអាមេរិក ទាំងការទាំងដើម ហើយខ្ញុំយកទៅចងការបន្តទៀត ។

ស.ឆ: ក្រោយពីខ្ញុំបានខ្ចីលុយសរុបចំនួន ១០ម៉ឺនដុល្លារពីដើមបណ្ដឹងហើយ ខ្ញុំក៏បានចេញសែក មូលប្បទានបត្រឲ្យគាត់ចំនួន ៣សន្លឹក ដោយដាក់ឈ្មោះ ដើមបណ្ដឹងឈ្មោះ ប៉ោយ ស្មី

(15

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធ៥**

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ «ឆ»

សំណុំរឿងព្រហ្មទណ្ឌលេខ: ៥[redacted]

ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦

សំណុំរឿងស៊ើបសួរលេ[redacted]

ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

លេខ [redacted] ឆ.ដ.ព.ស

## ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

យើង [redacted] ក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

អមដោយលោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញមាត្រា២០៣ ដល់មាត្រា២០៦ និងមាត្រាផ្សេងៗទៀត នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣៥៧២ អ.យ.ច ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបានបើកការស៊ើបសួរលើ:

-ឈ្មោះ [redacted] ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ កើតនៅឃុំថុក ស្រុកសូង ខេត្តកំពង់ចាម អាសយដ្ឋានបច្ចុប្បន្នភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (ស្លាប់) ម្ដាយឈ្មោះ ចាន់ លី (រស់) ប្រពន្ធឈ្មោះ ថុល ម៉េងហ៊ួយ (លែងលះ) មានកូន ០៣នាក់ អនីតិជន ☐ នីតិជន ☑ ។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ឃាត់ខ្លួនថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ (សំណុំរឿងព្រហ្មទណ្ឌលេខ ៥៦៥២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦) ។

-ជននេះត្រូវបានដាក់នៅក្រោមការពិនិត្យពីបទ: **លួចលក់អចលនវត្ថុអ្នកដទៃ** ប្រព្រឹត្តនៅភូមិ៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

-បានឃើញកំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង ។

-បានឃើញកំណត់ហេតុស្ដីពីការពិភាក្សាដេញដោល និងការកត់សម្គាល់របស់ភាគី ។

I-ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១-ក្នុងករណីបច្ចុប្បន្នជនត្រូវចោទឈ្មោះ [redacted] ត្រូវចោទពីបទ **លួចលក់អចលនវត្ថុអ្នកដទៃ** ប្រព្រឹត្តនៅភូមិ៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

-បានឃើញកំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង ។

២-ប្រព្រឹត្តនៅ ៖ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ឈ្មោះ [redacted] បានចុះកិច្ចសន្យាទិញ-លក់ដីមួយកន្លែងដែលមានទំហំ ៥៧៩៥៣ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិ៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មានព្រំប្រទល់ ខាងជើងទល់នឹងឈ្មោះ [redacted] ត្បូងទល់នឹងឈ្មោះ [redacted] ខាងកើតទល់នឹងផ្លូវមាត់ទន្លេ និងខាងលិចទល់នឹងផ្លូវព្រះរាម ជាមួយឈ្មោះ ជាម ហៃ ក្នុងតម្លៃ USD២,៥(ពីរដុល្លារ និងហាសិបសេន) ក្នុង ១ម៉ែត្រការ៉េ ដោយបានប្រគល់ប្រាក់កក់ទៅឲ្យឈ្មោះ [redacted] ចំនួន USD២០០០(ពីរពាន់ដុល្លារអាមេរិក) នៅថ្ងៃចុះកិច្ចសន្យា ។ បន្ទាប់មកឈ្មោះ ស[redacted] ពុំបានប្រគល់ប្រាក់ថ្លៃដីគ្រប់ចំនួនទៅឲ្យឈ្មោះ [illegible]

TNAOT

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាបង្គាប់ឱ្យឃុំខ្លួន

**ឧបសម្ព័ន្ធ៦**

ចៅក្រមស៊ើបសួរ "ឈ" យើ... ...ទចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

លេខ.................ង.ឃ.ឃ

-បានឃើញ មាត្រា ២០៦ ,២១៩ ,២២០ ,២២១ និងមាត្រា ២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៦៤ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ៥៩១០ អ.ឃ.ង ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩

-បានឃើញ សំណុំរឿងស៊ើបសួរលេខ: ៥៤៥៨ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលទាក់ទងនឹង:

នាមត្រកូល ...រី នាមខ្លួន ...ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិអូរបែកក្អម សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះគ្មានលេខ ផ្លូវលំ ភូមិទ្រេស សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ ...ា "រ" ម្ដាយឈ្មោះ ...ក "រ" នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី១២ ប្រវត្តិនៃការផ្ដន្ទាទោសពីមុន គ្មាន។

-ឃាត់ខ្លួន នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ: លួចមានស្ថានទម្ងន់ទោស (អក់ខ្សែសង្វៀង) ប្រព្រឹត្តនៅចំណុច មុខក្រុមហ៊ុនណេងហ៊ីបហ្វាយណែន ផ្លូវបេតុង ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ... ......ម៉ោងប្រហែល ១៦ និង ៣០នាទី តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញ ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ:......9118..........ឃ.ព.ស ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩

## បង្គាប់

១-ឱ្យភ្នាក់ងារមានសមត្ថកិច្ច នៃកងកម្លាំងសាធារណៈធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ ...ភេទប្រុស អាយុ ២២ ឆ្នាំ ទៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួន "មខ" ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ។

២-ឱ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន"មខ" ទទួល និងឃុំខ្លួនជននេះរហូត ដល់មានបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

៣-ឱ្យគ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់សហការអនុវត្តឱ្យបានល្អនៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែកត្ដិក ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធ៧**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ចូល ថ្ងៃទី ១៤ ខែ ១១ ឆ្នាំ ២០១៩ ម៉ោង ១០ នាទី

**<u>ពាក្យសុំនៅក្រៅឃុំបណ្ដោះអាសន្ន</u>**

នាងខ្ញុំឈ្មោះ អាយុ៣៩ឆ្នាំ បច្ចុប្បន្នកំពុងជាប់ឃុំឃាំងនៅ ពន្ធនាគារខេត្តកំពតតាមអំណាចដីកាបង្គាប់អោយឃុំខ្លួនលេខ ៨៨៣ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៩របស់សាលាដំបូងខេត្តកំពត ។

**<u>សូមគោរពចូលមក</u>**

**លោក ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត**

<u>សូមមេត្តាជ្រាប</u> ។

ដោយនាងខ្ញុំ ត្រូវជាប់ចោទពីបទៈ រួមគំនិតក្បត់ ហើយនាងខ្ញុំ សុំនៅក្រៅឃុំ ដើម្បីបានទៅរួមរស់ជាមួយប្ដី និងកូន ព្រមទាំងមានទីលំនៅ ពិតប្រាកដដែលស្ថិតនៅភូមិ ទឹកក្រហម ឃុំកណ្ដោលស្រុក ទឹកឈូ ខេត្តកំពត ។

ដូច្នេះនាងខ្ញុំ សំណូមពរលោកចៅក្រម មេត្តាអនុញ្ញាតអោយនាងខ្ញុំ បាននៅក្រៅឃុំបណ្ដោះអាសន្ន ដើម្បីបានទៅរួមរស់ជាមួយប្ដី និងកូន ហើយនាងខ្ញុំ សូមសន្យាថាចូលខ្លួនមកតុលាការគ្រប់ពេលនៅពេលដែលតុលាការកោះហៅ ។

អាស្រ័យហេតុនេះ សូមលោកចៅក្រមស៊ើបសួរ មេត្តាជួយដោះស្រាយសំណូមពរ របស់នាងខ្ញុំដោយក្ដីអនុគ្រោះ ។

សូមលោក ចៅក្រមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ!

ថ្ងៃព្រហស្បតិ៍៣រោចខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កំពត.ថ្ងៃទី១៤ខែ វិច្ឆិកា ឆ្នាំ ២០១៩

**ស្នាមមេដៃស្ដាំ**

លេខ ក.កព

បានឃើញ និង បញ្ជាក់ថា

ស្នាមមេដៃនេះពិតជារបស់ឈ្មោះ

កំពុងឃុំឃាំងនៅក្នុងពន្ធនាគារប្រាកដមែន ។

ថ្ងៃ ព្រហស្បតិ៍៣រោច ខែកត្តិក ឆ្នាំកុរឯកស័ក ព.ស ២៥៦៣

កំពត.ថ្ងៃទី១៤ខែ វិច្ឆិកា ឆ្នាំ ២០១៩

**ប្រធានពន្ធនាគារ**

(១៤)

**ឧបសម្ព័ន្ធ៨**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកណ្ដាល

លេខ: ...........(គ)

## ដីកាបញ្ជូនឱ្យឆ្លើយ

យើង អនុប្រធាននៃសាលាដំបូងខេត្តកណ្ដាល

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ០៦៨ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

បានឃើញ កំណត់ហេតុហេតុទទួលវត្ថុតាង ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

បានឃើញ ពាក្យស្នើសុំអត្តសញ្ញាណប័ណ្ណ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ របស់ឈ្មោះ ។

បញ្ជាឱ្យបញ្ជូនសំណុំរឿងស៊ើបសួរទាក់ទងនឹងជនត្រូវចោទដែលមានដូចខាងក្រោម៖

ឈ្មោះ ភេទប្រុស អាយុ៤៨ឆ្នាំ មុខរបររត់ម៉ូតូឌុប មានទីកន្លែងកំណើតនៅភូមិចំណោម ឃុំកំពែង ស្រុកព្រៃកប្បាស ខេត្តតាកែវ និងទីលំនៅស្នាក់នៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ប្រពន្ធឈ្មោះ (រ) មានកូនបីនាក់ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ទោសពីមុន "គ្មាន" (ក្រៅឃុំ) ។

<u>ត្រូវដាក់អោយស្ថិតនៅក្រោមការពិនិត្យពីបទ:</u> លួច ប្រព្រឹត្តនៅភូមិក្រពើហារ ឃុំព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧ តាមមាត្រា ៣៥៣ និងមាត្រា៣៥៦ នៃ*ក្រមព្រហ្មទណ្ឌ* ។

ទៅតំណាងរអយ្យការ ដើម្បីធ្វើសេចក្ដីសន្និដ្ឋាន ឬផ្ដល់យោបល់លើពាក្យស្នើសុំអត្តសញ្ញាណប័ណ្ណរបស់ឈ្មោះ ។

ខេត្តកណ្ដាល, ថ្ងៃទី..១៨.... ខែមីនា ឆ្នាំ២០១៧

**អនុប្រធានសាលាដំបូង**

បានទទួលរបនុវត្ត

**ក្រឡាបញ្ជី**

<u>យោបល់របស់តំណាងអយ្យការ</u>

យើង តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល

-បានឃើញដីកាបញ្ជូនឱ្យឆ្លើយខាងលើ

-បានឃើញ ពាក្យស្នើសុំអត្តសញ្ញាណប័ណ្ណ របស់ឈ្មោះ

ក្រោយពីបានពិនិត្យសំណុំរឿងស៊ើបសួរចប់ ស្នើសុំ៖

[illegible]............................................................

...............................................................................................................។

ខេត្តកណ្តាល, ថ្ងៃទី[illegible]......ខែ[illegible]......ឆ្នាំ២០១៧

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធ៩**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**********

សាលាដំបូងខេត្តកណ្ដាល

លេខ ... កសក្រយ

## ដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំ
## បណ្ដោះអាសន្ន

**********

**យើង** អនុប្រធានសាលាដំបូងខេត្តកណ្ដាល

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ ០៦៨ អ.ក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ០៦៥ ដកសស ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

បានឃើញដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខៈ ២០៨ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧

បានឃើញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខៈ ២០៩ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧

បានឃើញពាក្យសុំចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ របស់លោកមេធាវី ត្រូវជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ បានសុំនៅក្រៅឃុំជាបណ្ដោះអាសន្ន ។

បានឃើញលិខិតបញ្ជាក់សុខភាព ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ។

ក្រោយពីបានពិនិត្យមើលសំណុំរឿង និងពាក្យសុំនេះចប់សព្វគ្រប់

### យល់ឃើញថា

-ស្ថានភាពសុខភាពរបស់ជនត្រូវចោទមិនល្អប្រសើរ ដែលទាមទារឱ្យពេទ្យជំនាញពិនិត្យព្យាបាល ដូចមានលិខិតបញ្ជាក់សុខភាពចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ពន្ធនាគារខេត្តកណ្ដាល ។

-ជនជាប់ចោទមានប្រពន្ធជាកម្មការិនីរោងចក្រ ដែលនៅក្រោងចក្របានបិទទ្វារមិនបានបើកប្រាក់បៀវត្សចំនួន ០១ (ប្រាំមួយ) ខែមកហើយ ដែលបានធានាជនត្រូវចោទជាប្ដីឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ។

-ដើមបណ្ដឹងបានដកពាក្យឈប់ប្ដឹងផ្ដល់ ។

-ជនត្រូវចោទ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពិចារណា ការស៊ើបសួរមានលក្ខណៈជឿនលឿន ការឱ្យជនត្រូវចោទនៅក្រៅឃុំបណ្ដោះអាសន្នមិនប៉ះពាល់ដល់នីតិវិធីស៊ើបសួរទេ ហើយតុលាការនឹងដាក់ជននេះឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

### ហេតុដូច្នេះ សម្រេច

ឱ្យឈ្មោះ ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបររត់ម៉ូតូឌុប ទីលំនៅបច្ចុប្បន្ននៅភូមិចំណោម ឃុំកំពែង ស្រុកព្រៃកប្បាស ខេត្តតាកែវ ដែលជាប់ចោទពីបទ៖ លួច ប្រព្រឹត្តនៅភូមិក្រពើហារ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧ ហើយដែលត្រូវបានឃុំខ្លួននៅពន្ធនាគារខេត្តកណ្ដាល លេខឃុំខ្លួន ២០៩ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ បាននៅក្រៅឃុំបណ្ដោះអាសន្ន តែត្រូវឱ្យឈ្មោះនេះចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការជារាងរាល់ពេលណាមានដីកាកោះហៅ។

[illegible]
បានទទួលដំណើររួចហើយ [illegible]

ថ្ងៃទី.......ខែ...........ឆ្នាំ២០១៧

ព្រះរាជអាជ្ញា

តាខ្មៅ, ថ្ងៃទី.......ខែ.......ឆ្នាំ២០១៧

**អនុប្រធានសាលាដំបូង**

**ឧបសម្ព័ន្ធ១០**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរៈ ម ' -
លេខៈ [redacted] ម.ជ.យ.ជ

## ដីកាបង្គាប់ឲ្យដោះលែង

យើង [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ និងជាចៅក្រមស៊ើបសួរ

- **បានឃើញ** ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩។
- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៥៣១២ អ.យ.ង ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- **បានឃើញ** សំណុំរឿងស៊ើបសួរលេខ [redacted] ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩។
- **បានឃើញ** ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៨៧៣៨ "ម".ង.ព.ស ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ២០១៩។
- **បានឃើញ** ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ១២៩៦២ "ម".ង.ឃ.ង ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩។
- **បានឃើញ** ដីកាសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្នលេខ..................... "ម" .ង.ព.ស ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

### ហេតុដូច្នេះសម្រេច

បង្គាប់មកលោកប្រធានមណ្ឌលអប់រំកែប្រែទី១ (ម១) ឲ្យដោះលែងឈ្មោះ [redacted] ភេទប្រុស អាយុ ៧០ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិសំបួរមាស ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ១៦បេ ផ្លូវលេខ១៩ ភូមិត្រពាំងថ្លឹង៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣នាក់ ជាតិជន ទោសពីមុនគ្មាន **ជាបន្ទាន់បើជននេះមិនជាប់ពាក់ព័ន្ធនឹងដីកាឃុំ ខ្លួនដែលបទល្មើសផ្សេងទៀតទេនោះ។**

ថ្ងៃព្រហស្បតិ៍ ០៣រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩

**ចៅក្រមស៊ើបសួរ**

[redacted]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

ចៅក្រមស៊ើបសួរ "គ"

សំណុំរឿងព្រហ្មទណ្ឌលេខ [redacted]

ចុះថ្ងៃទី១៣-០៣-២០២០

លេខ: [redacted] ស.ឃខ/២០

**ឧបសម្ព័ន្ធ១១**

## ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល អមដោយ លោក [redacted] ក្រឡាបញ្ជី ។

- បានឃើញមាត្រា២០៣, ២០៤, ២០៥ និងមាត្រា២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: [redacted] ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ ដែលបានបើកឲ្យស៊ើបសួរទាក់ទងនឹង:

ឈ្មោះ [redacted] ភេទប្រុស អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ កម្រិតវប្បធម៌ថ្នាក់ទី០៩ចាស់ ទីកន្លែងកំណើតនៅភូមិចាក់អង្រែ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្ននៅភូមិព្រែកតាឡុង សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣នាក់ ទោសពីមុនគ្មាន ។

ជននេះត្រូវបានដាក់នៅក្រោមការពិនិត្យពីបទ: "**ឆបោក, រំលោភលើទំនុកចិត្ត និងលួចលក់អចលនវត្ថុអ្នកដទៃ**" ប្រព្រឹត្តនៅភូមិព្រែកអុងប៉ាង ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្ដាល កាលពីឆ្នាំ ២០១៦-២០១៩ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៣៧៧, មាត្រា៣៧៨, មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា២៥៥ នៃច្បាប់ភូមិបាល ។

- បានឃើញកំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង
- បានឃើញកំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ
- បានឃើញកំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទ

### I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់:

១. ក្នុងករណីបច្ចុប្បន្នជនត្រូវចោទឈ្មោះ [redacted] ត្រូវបានដាក់នៅក្រោមការពិនិត្យ ពីបទ: "**ឆបោក, រំលោភលើទំនុកចិត្ត និងលួចលក់អចលនវត្ថុអ្នកដទៃ**" ប្រព្រឹត្តនៅភូមិព្រែកអុងប៉ាង ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្ដាល កាលពីឆ្នាំ ២០១៦-២០១៩ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៣៧៧, មាត្រា៣៧៨, មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធ១២**

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ (ត)
លេខ [redacted] ច.ព.ស

# ដីកាសម្រេច

## ដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក [redacted] ជាក្រឡាបញ្ជី

-បានឃើញ មាត្រា ២២៣ និងមាត្រាពាក់ព័ន្ធក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៧។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៥២៨ អ.យ.ប ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ [redacted] ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧។

## សំអាងហេតុ

ដោយហេតុផលសុខភាពរបស់ជនត្រូវចោទ និងដើម្បីធានាឲ្យជនត្រូវចោទមានវត្តមានចំពោះមុខតុលាការ និងដើម្បីជៀសវាងការរាំងស្ទះក្នុងនីតិវិធីស៊ើបសួរ គប្បីដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមបញ្ញត្តិមាត្រា ២២៣ , ២២៦ និងមាត្រា ២៣០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

## ហេតុដូច្នេះសម្រេច

១/ដាក់ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ៦៥ឆ្នាំ មុខរបរ អ[redacted] កន្លែងកំណើតនៅភូមិត្រពាំងត្រគៀត ឃុំឧត្តមសុរិយា ស្រុកត្រាំកក់ ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួន ស្នាក់នៅផ្ទះលេខ៥៧A ផ្លូវលេខ៣១៣ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] (រ) មានកូន០២នាក់ ឪពុកឈ្មោះ [redacted]ប) ម្ដាយឈ្មោះ [redacted]) ជាតិខ្មែរ ទោសពីមុនគ្មាន ដែលត្រូវចោទប្រកាន់ពីបទ **សន្ទិដ្ឋិភាពជាមួយបរទេស** ប្រព្រឹត្តនៅប្រទេសកម្ពុជា និងទីកន្លែងផ្សេងទៀត កាលពីអំឡុងឆ្នាំ១៩៩៣ ដល់ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤៤៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ **ដោយត្រូវគោរពកាតព្វកិច្ចមួយចំនួនដូចខាងក្រោម ៖**

**ក-ក្រៅពីលំនៅឋានដែលមានទីតាំងស្ថិតនៅលើផ្លូវលេខ៣១៣,** មិនត្រូវចេញក្រៅពីព្រំប្រទល់នៃដែនដីដែលខណ្ឌដោយផ្លូវលេខ៣១៣ ផ្លូវលេខ៣១១ និងផ្លូវលេខ៦០៨។ ព្រំប្រទល់នៃដែនដីនេះមានភ្ជាប់ជាឧបសម្ព័ន្ធនៃដីកាសម្រេចនេះ។ ក្នុងករណីចាំបាច់ ដោយសារហេតុផលសុខភាពដែលត្រូវចាកចេញពីព្រំប្រទល់ដែនដីនេះ ត្រូវរាយការណ៍សុំការអនុញ្ញាតពីចៅក្រមស៊ើបសួរ ឬចៅក្រមដែលមានសមត្ថកិច្ច ។

ខ-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

គ-មិនត្រូវជួបបុគ្គលមួយចំនួនដូចបញ្ជាក់ជូនខាងក្រោម ៖

១. [redacted]

២. ជនបរទេស ជាពិសេស ជនបរទេសដែលអាចមានការពាក់ព័ន្ធនឹងសំណុំរឿង

ក្នុងករណីមានចម្ងល់ ត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ ឬចៅក្រមដែលមានសមត្ថកិច្ច ដើម្បីសុំការអនុញ្ញាតទទួលជួបបុគ្គលណាមួយ។

ឃ-មិនត្រូវធ្វើសកម្មភាពជួបជុំក្នុងគោលដៅនយោបាយ ឬសកម្មភាពនយោបាយផ្សេងទៀត

២/ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ ត្រូវអនុវត្តតាមដីកាសម្រេចនេះ និងរាយការណ៍ជូនចៅក្រមស៊ើបសួរ ក្នុងករណីដែលជនត្រូវចោទមិនគោរពតាមកាតព្វកិច្ចខាងលើ។

៣/ប្រសិនបើជនត្រូវចោទគេចវេះដោយចេតនា ពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នបាន។

បានទទួលដំណឹង

ថ្ងៃអាទិត្យ ១៤រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ[redacted]

**ចៅក្រមស៊ើបសួរ**

[redacted]

ថ្ងៃអាទិត្យ១៤រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៨

**តំណាងអយ្យការ**

[redacted]

**ក្រឡាបញ្ជី**

[redacted]

**ឧបសម្ព័ន្ធ១៣**


សាលាដំបូងរាជធានីភ្នំពេញ
មន្ទីរស៊ើបសួរ -ន-
លេខ: [redacted] តព្រ


# ដីកាបង្គាប់ឲ្យចាប់ខ្លួន

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញមាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២០១៣ អ.យ.ង ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ លេខ ១៩១៤១ តព្រ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនឲ្យឆ្លើយ លេខ ២០០០០ តព្រ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

**ក្រោយពីបានពិនិត្យលើសំណុំរឿងទាំងមូលហើយ ឃើញថា:**

-ឈ្មោះ [redacted] ប្រុស កើតថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៤៩ សញ្ជាតិខ្មែរ តួនាទី ប្រធានគណបក្សសង្គ្រោះជាតិ កាន់លិខិតឆ្លងដែនលេខ D0002190 កើតនៅសង្កាត់លេខ២ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះលេខ៥៧៦ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន០៣នាក់ កំរិតវប្បធម៌ បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសសេដ្ឋកិច្ច ជានីតិជន ត្រូវចោទប្រកាន់ពីបទ **សមគំនិតក្នុងអំពើក្លែងបន្លំឯកសារសាធារណៈ , ប្រើប្រាស់ឯកសារសាធារណៈក្លែង និងញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១២ និង១៣ ខែសីហា ឆ្នាំ២០១៥ អំពើដែលមានបញ្ញត្តិនិងផ្តន្ទាទោសតាមមាត្រា២៩, មាត្រា៦២៩ ,មាត្រា៦៣០ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ ។

-ឈ្មោះ [redacted] ត្រូវបានចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យចូលខ្លួន ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥ តែជននេះពុំបានមកបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរ តាមការកំណត់ឡើយ ។

-តំណាងអយ្យការបានផ្តល់យោបល់ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ បញ្ជាក់ថា: ផ្អែកលើចំណារបាយការណ៍ប៉ុស្តិ៍រដ្ឋបាលឈ្មោះខាងលើពុំស្ថិតនៅក្នុងមូលដ្ឋានឡើយ ក្រោយពីតុលាការបានកោះហៅបង្គាប់ឲ្យចូលខ្លួន ដូច្នេះឯកភាពលោកចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះខាងលើ ដើម្បីទុកជូនតុលាការចាត់ការតាមច្បាប់ ។

## ហេតុដូច្នេះសម្រេច

១-បញ្ជាដល់កងកម្លាំងសាធារណៈ ឲ្យស្រាវជ្រាវរកចាប់ និងឲ្យនាំខ្លួន [redacted] ដែលមានអត្តសញ្ញាណខាងលើនេះ ទៅក្នុងមណ្ឌលអប់រំកែប្រែ នៃក្រសួងមហាផ្ទៃ ។

២-បញ្ជាដល់ប្រធានមណ្ឌលអប់រំកែប្រែ នៃក្រសួងមហាផ្ទៃ ឲ្យទទួល និងឃុំខ្លួនបុគ្គលនោះ ។

រាជធានីភ្នំពេញ ថ្ងៃទី 09 ខែធ្នូ ឆ្នាំ២០១៥

**ចៅក្រមស៊ើបសួរ**

[redacted]


អាសយដ្ឋាន: អាគារលេខ ២៥-២៧ ផ្លូវលេខ ២១៧.២១៣ សង្កាត់វាលវង់ ខណ្ឌ ៧ មករា, ភ្នំពេញ ទូរសារ-ទូរស័ព្ទ: (៨៥៥)-២៣ ៨៨៥ ៩៦១/២៣ ៨៨៥ ៩៦២
Adress : #25-27, Street 217-213, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia Fax-Phone : (855)-23 885 961 / 23 885 962